# សេចក្ដីបន្ថែម

I

# ប្រវត្តិសង្ខេបនៃព្រះពុទ្ធសាសនា

## ១- ប្រទេសឥណ្ឌា

ព្រឹត្តិការណ៍ដ៏ធំមួយក្នុងប្រវត្តិជំនឿសាសនា ដែលគួរកត់សម្គាល់ បានកើតឡើង នៅពេលដែល «ពន្លឺអាស៊ីទ្វីប» ចាប់មានរស្មីភ្លឺត្រចេះត្រចង់ នៅក្នុងភូមិភាគកណ្ដាលនៃប្រទេសឥណ្ឌា។ បើនិយាយម្យ៉ាងទៀតគឺ នៅពេលនោះមហាប្រាជ្ញាញាណ និងមហាករុណាអាសូរនៃព្រះពុទ្ធបានចាប់ផ្ដើម ផុសចេញឡើង បណ្ដុះបណ្ដាល ទាក់ទាញចិត្តមនុស្សលោកជាបន្តបន្ទាប់រាប់សតវត្សរហូតមកទល់សព្វថ្ងៃនេះ។

ព្រះពុទ្ធគោតម ដែលពុទ្ធសាសនិកទាំងឡាយស្គាល់ព្រះអង្គក្នុងព្រះនាមថា ព្រះសក្យមុនី ព្រះអង្គជា «អ្នកប្រាជ្ញបណ្ឌិតក្នុងកុលសម្ព័ន្ធសក្យ» ព្រះអង្គទ្រង់បានចាកចោលព្រះរាជដំណាក់ ប្រែភេទជាសមណ ហើយបោះជំហានឈានឆ្ពោះទៅទិសខាងត្បូងនៃមគធនគរ។ តាមការស្មានយល់នៃជនទាំងឡាយគឺ ព្រះអង្គទ្រង់បានសម្រេចពន្លឺត្រាស់ដឹង នៅពាក់កណ្ដាលសតវត្សទី៦ មុនគ្រិស្តសករាជ នៅក្រោមដើមពោធិព្រឹក្ស។ ចាប់តាំងពីពេលនោះរហូតមកទល់ពេលព្រះអង្គចូលមហាបរិនិព្វាន គឺក្នុងអំឡុង៤៥ឆ្នាំ ព្រះអង្គទ្រង់បានបំពេញពុទ្ធកិច្ច ផ្សាយព្រះសាសនា ប្រោសសត្វលោក ដោយគ្មានគិតដល់ការនឿយហត់របស់ព្រះអង្គឡើយ។ វត្តអារាមនៃពុទ្ធសាសនា ក៏ចេះតែមានចំនួនកើត

ច្រើនឡើងជាលំដាប់ នៅក្នុងរាជាណាចក្រទាំងឡាយ ក្នុងកុលសម្ព័ន្ធទាំងឡាយនាប្រទេសឥណ្ឌាភាគកណ្ដាល។

ក្នុងរជ្ជកាលស្ដេច អសោក ក្សត្រទី៣ក្នុងសន្តតិវង្សមោរ្យ សោយរាជ្យពីឆ្នាំ ២៦៨ ដល់ឆ្នាំ ២៣២ មុនគ្រិស្តសករាជ សាសនាព្រះពុទ្ធគោតម ត្រូវបានផ្សព្វផ្សាយពាសពេញប្រទេសឥណ្ឌាទាំងមូល រហូតដល់ទៅប្រទេសក្រៅទៀតផង។

នគរមោរ្យ ជារដ្ឋទី១ ក្នុងចំណោមនគរធំៗ នៃឥណ្ឌាទ្វីប។ ក្នុងរាជ្យស្ដេចទី១ ព្រះនាម ចន្ទ្រគុប្ត ប្រហែលឆ្នាំ ៣១៧-២៩៣ មុនគ្រិស្តសករាជ នគរនេះមានដែនដីធំធេងជាស្រេច ទៅខាងជើងលាតសន្ធឹងដល់ជួរភ្នំហេមពាន្ត ទៅខាងកើតលាតសន្ធឹងដល់ឈូងសមុទ្របង់ហ្គាល ទៅខាងលិចលាតសន្ធឹងដល់ជួរភ្នំហិន្ទុគុស្ហ នៅខាងត្បូងលាតសន្ធឹងដល់ជួរភ្នំវិនធ្យ។ ព្រះបាទអសោកទ្រង់បានពង្រីកទឹកដីជាបន្តទៅទៀត នៅតាមខ្ពង់រាប នៃតំបន់ ដេក្កង់ ដោយព្រះអង្គបានច្បាំងយកតំបន់ កលិង្គ និងតំបន់ឯទៀតជាច្រើន។

មានគេនិយាយថា ស្ដេចអង្គនេះមានចរិតឆេវឆាវ ឆាប់ខ្ញាល់ណាស់ រហូតដល់មានព្រះនាមមួយទៀតថា ចន្ទាសោក ឬស្ដេចកំហឹងអសោក។ ប៉ុន្តែក្រោយមក ស្ដេចអង្គនេះបានកែប្រែចរិតខឹងក្រោធចោលចេញអស់ នៅពេលដែលព្រះអង្គទ្រង់បានយល់នូវលទ្ធផលខូចខាតធំ ក្នុងសង្គ្រាមជាមួយនគរកលិង្គ ហើយព្រះអង្គ ក៏បានទៅជាអ្នកជឿតាមសាសនាព្រះពុទ្ធយ៉ាងស្មោះស្ម័គ្របំផុតម្នាក់។ ចាប់តាំងពីពេលនោះមក ព្រះអង្គទ្រង់បានកសាងកុសលជាច្រើន ក្នុងភារៈជាអ្នកកាន់ព្រះពុទ្ធសសនា។ ក្នុងចំណោមកុសលធំៗ ទាំងឡាយមានកុសលពីរជាពិសេស ដែលគួរកត់សម្គាល់។

សមិទ្ធិទី១ គឺ «រាជបញ្ញត្តិព្រះអសោក» ដែលជាគោលច្បាប់សម្រាប់រាជរដ្ឋាភិបាល ដែលយោលយកព្រះពុទ្ធសាសនាជាគ្រឹះ។ ព្រះអង្គទ្រង់បញ្ជាឲ្យគេចារិកគោលច្បាប់ទាំងនោះ ទុកនៅលើសសរថ្ម និងជញ្ជាំងថ្ម ដែលជាកិច្ចមួយបណ្តាលឲ្យ ព្រះពុទ្ធសាសនារឹតតែបានរីកសុសសាយឡើង។

សមិទ្ធិទី២ គឺ ព្រះអង្គទ្រង់បានបញ្ជូនគណៈបេសកកម្ម ទៅគ្រប់ទិសតំបន់ដើម្បីផ្សាយព្រះពុទ្ធសាសនា។ ជាពិសេសគួរកត់សម្គាល់គឺ គណៈបេសកកម្មទាំងឡាយដែលត្រូវបានបញ្ជូនទៅភូមិភាគដូចជា ប្រទេសស៊ីរី ប្រទេសអេហ្ស៊ីប ប្រទេសលីប៊ី ប្រទេសម៉ាសេដ្វាន និងប្រទេសអេពៀរ៍ បានផ្សាយព្រះពុទ្ធសាសនាពាសពេញបស្ចិមទ្វីប។ ក្រៅពីនេះ អ្វីដែលគួរកត់សម្គាល់ដែរគឺ សាសនទូតឈ្មោះ មហេន្ទ ដែលត្រូវបានបញ្ជូនទៅប្រទេសសិរីលង្កា បានទទួលមហាជោគជ័យក្នុងការរៀបចំផ្សាយសាសនាប្រសើរបំផុតនេះ នៅក្នុងលង្កាទ្វីប ហើយបានបង្កើតមូលដ្ឋានដើម្បីចេញផ្សាយព្រះពុទ្ធសាសនាលើកោះទាំងមូល។

## ២- ដើមកំណើតពុទ្ធសាសនាមហាយាន

«ចលនាពុទ្ធសាសនាឆ្ពោះទៅទិសខាងកើត» ទើបតែត្រូវបានពុទ្ធសាសនិកទាំងឡាយនាំគ្នានិយាយជាញឹកញាប់ ក្នុងរយៈប៉ុន្មានសតវត្សចុងក្រោយនេះទេ។ ប្រវត្តិសាស្ត្របញ្ជាក់ឲ្យឃើញថា ពុទ្ធសាសនាបានបែរមុខឆ្ពោះទៅទិសខាងលិច តាំងពីច្រើនសតវត្សមុនគ្រិស្តសករាជមកហើយ ទើបតែនៅមុនគ្រិស្តសករាជបន្តិច ឬក្រោយនោះបន្តិចនេះទេ ដែលពុទ្ធសាសនាចាប់បែរមុខឆ្ពោះទៅទិសខាងកើត។

ប៉ុន្តែមុននឹងចូលដល់រឿងនេះ យើងត្រូវនិយាយអំពី ការប្រែប្រួលធំមួយនៅក្នុងប្រវត្តិពុទ្ធសាសនា។ ការប្រែប្រួលនេះ គឺ«ចលនាថ្មី» ដែលមានឈ្មោះថា ពុទ្ធសាសនាមហាយាន ឬពុទ្ធសាសនាយានធំ ដែលចាក់ឫសយ៉ាងជ្រៅ ហើយដុះចេញឡើងជាមែកធាងយ៉ាងធំ នៅក្នុងពុទ្ធសាសនា នាពេលនោះ។

តើ «ចលនាថ្មី» នេះចាប់កំណើតយ៉ាងដូចម្ដេច នៅទីកន្លែងណា? គ្មាននរណាម្នាក់អាចផ្ដល់ចម្លើយឲ្យបានច្បាស់លាស់ ពិតប្រាកដ ក្នុងរឿងនេះទេ។ ចំពោះរឿងនេះ យើងអាចបញ្ជាក់បានតែព្រឹត្តិការណ៍ខ្លះៗ ដូចតទៅនេះ : ទី១ គឺ និន្នាការដែលត្រូវតែកើតឡើងនៅក្នុងគំនិតនៃមហាសង្ឃិកនិកាយ ក្នុងចំណោមពពួកសង្ឃជឿនលឿនជាងគេក្នុងពេលនោះ។ ព្រឹត្តិការណ៍ទី២ គឺគោលសំខាន់ខ្លះនៃគម្ពីរមហាយាន មានតាំងពីក្នុងសតវត្សទី១ មុនគ្រិស្តសករាជមកម៉្លេះ។ ហើយនៅពេលដែលគតិដ៏ប្រសើរថ្លៃថ្លា នៃព្រះថេរៈ **នាគាវជុនៈ** ដែលមានគម្ពីរមហាយានជាគ្រឹះ បានលូតលាស់មានសកម្មភាពឡើងពុទ្ធសាសនាមយាហាន ក៏មានពន្លឺចែងចាំងឡើង ភ្លឺជាងគេនៅក្នុងប្រវត្តិសាស្ត្រនាសម័យនោះ។

ក្នុងប្រវត្តិសាស្ត្រដ៏វែងនៃព្រះពុទ្ធសាសនា ពុទ្ធសាសនាមហាយានមានមុខងារសំខាន់ណាស់។ នៅក្នុងប្រទេស ដូចជាប្រទេសចិន ប្រទេសជប៉ុនជាដើម សឹងតែក្នុងរយៈពេលមួយចប់ប្រវត្តិសាស្ត្ររបស់គេ ព្រះពុទ្ធសាសនាត្រូវបានលូតលាស់ឡើងនៅក្រោមអានុភាពមហាយាន។ ក្នុងរឿងនេះ គ្មានអ្វីគួរឆ្ងល់ទេ ព្រោះមហាយានបានបង្កើតឧត្តមគតិថ្មីមួយក្នុងគោលបំណងស្រោចស្រង់មនុស្សជាស្រេចមកហើយ ដោយគិតទុកសន្តបុគ្គលថ្មីៗ ដែលមានជីវិត

រស់នៅៗឡើយ ជាពោធិសត្វ ដែលមានភារៈយកឧត្តមគតិនេះទៅអនុវត្ត ដើម្បីស្រោចស្រង់សត្វលោក។ ម្យ៉ាងទៀត គោលគំនិតនៃពួកទស្សនវិទូខាងមហាយានក្នុងការគាំទ្រឧត្តមគតិនេះតាមដោយបរមត្ថវិជ្ជា ឬចិត្តសាស្ត្រ ពិតជាវិសេសពន់ពេកណាស់។ តាមរបៀបនេះ គណៈមហាយានមានការទាក់ទងនឹងសេចក្តីប្រៀនប្រដៅរបស់ព្រះពុទ្ធគោតម ក៏ពិតហើយ តែមានអភិវឌ្ឍន៍ថ្មីៗជាច្រើន ដែលទាក់ទងនឹងព្រះប្រាជ្ញាញាណ ហើយនឹងព្រះមហាសន្តោសអាសូរត្រូវបានបន្ថែមទៅលើពុទ្ធឱវាទនេះ។ ដោយសារអភិវឌ្ឍន៍ថ្មីៗទាំងនេះ ព្រះពុទ្ធសាសនាមានសកម្មភាពជាខ្លាំង ហើយបានរីកចម្រើនជាពន្លឺកនៅចុងបូព៌ាប្រទេស ប្រដូចបានទៅនឹងចរន្តទឹកហូរខ្លាំងនៃទន្លេ។

## ៣- អាស៊ីកណ្តាល

គឺពីប្រទេសក្នុងភូមិភាគមជ្ឈិមអាស៊ីនេះហើយ ដែលប្រទេសចិនបានទទួលពុទ្ធសាសនាជាដំបូង។ ដូច្នេះ ដើម្បីបង្ហាញឲ្យឃើញថា តើសាសនានេះចេញពីប្រទេសឥណ្ឌាទៅប្រទេសចិនរបៀបណានោះ ជាការចាំបាច់ត្រូវតែនិយាយអំពី «ផ្លូវសូត្រ»។ ផ្លូវនេះ កាត់តាមភូមិភាគជំទូលាយឥតព្រំដែននៃអាស៊ីភាគកណ្តាល ក្នុងបំណងភ្ជាប់បូព៌ាទ្វីប នឹងបស្ចិមទ្វីប។ ផ្លូវសេដ្ឋកិច្ចនេះត្រូវបានបើកឡើង ក្នុងរាជ្យស្តេច វូ ១៤០-៨៧ មុនគ្រិស្ត ក្នុងសន្តតិវង្សហាន។ ក្នុងសម័យនោះ អំណាចចក្រពត្រនៃវង្សក្សត្រ ហាន បានវាតសន្ទឹងយ៉ាងឆ្ងាយឆ្ពោះទៅបស្ចិមទិស ដោយបានភ្ជាប់ភូមិភាគទាំងឡាយ ដូចជាប្រទេស តេរហ្គាន សុហ្គឌីយ៉ាន តុខារា បារថីយ៍ ជា ដើម។ គំនិតពាណិជ្ជ-

និយមដែលផុសឡើងជាដំបូង ពីអធិរាជ **អាឡិចសង់មហារាជ** មានសកម្ម-ភាពខ្លាំងក្លាជាទីបំផុត។ នៅតាមដងផ្លូវដែលកាត់តាមភូមិភាគទាំងនេះ សូត្រមានមុខងារសំខាន់ជាងគេបង្អស់ ក្នុងផ្នែពាណិជ្ជកម្ម។ ហេតុដូច្នេះហើយបានជា ផ្លូវនេះមានឈ្មោះថា «ផ្លូវសូត្រ»។ នៅមុនគ្រិស្តសករាជបន្តិច ឬក្រោយគ្រិស្តសករាជបន្តិច ប្រទេសឥណ្ឌា និងប្រទេសចិន ចាប់មានការទាក់ទងគ្នាខាងផ្នែកវប្បធម៌ តាមផ្លូវនេះឯង។ ដូច្នេះ គេអាចនិយាយបានដែរថា ផ្លូវនេះជា«ផ្លូវផ្សាយព្រះពុទ្ធសាសនា»។

## ៤- ប្រទេសចិន

ប្រវត្តិពុទ្ធសាសនាចិន ចាប់ផ្តើមឡើង នៅពេលបានទទួលគម្ពីរពុទ្ធ-សាសនា ហើយចាប់បកប្រែគម្ពីរទាំងនោះ។ ស្នាដៃនិពន្ធដែលចាស់ជាងគេនាបូរាណកាលនោះ បើតាមគេនិយាយគឺមាន «ព្រះសូត្រ ៤២ មាត្រា» ឬជាភាសាចិនថា ស៊ឺស៊ិញអែរចាងជិង និពន្ធដោយព្រះថេរៈ កាស្យបមាតង្គ និងស្នាដៃឯទៀតៗ ក្នុងសម័យ យីងប៉ិង ៥៨-៧៦ នៃគ្រិស្តសករាជ ក្នុងរាជ្យស្តេចមិញ នៃសម័យខាងក្រោយបន្តិរបស់ហានផ្នែកខាងកើត។ ប៉ុន្តែសព្វថ្ងៃនេះគេទុករឿងតំណាលនេះ ជារឿងព្រេងទៅវិញ។ សព្វថ្ងៃនេះ តាមមតិដែលយោលទៅតាមកស្តុតាងគ្រប់គ្រាន់ គឺព្រះថេរៈ អានស៊ិនកៅ ដែលបានបកប្រែមុនដំបូង នៅ លោយ៉ាង ពីឆ្នាំ ១៤៨ ដល់ ១៧១។ ចាប់តាំងពីពេលនោះរហូតមកដល់សន្តតិវង្ស សុង ខាងដើង ឆ្នាំ ៩៦០-១១២៩ ការប្រែភាសាត្រូវបានធ្វើជាបន្តបន្ទាប់ ក្នុងរយៈពេលជិតមួយពាន់ឆ្នាំ។

ជាច្រើនឆ្នាំមុនដំបូង អ្នកនាំចូល និងបកប្រែគម្ពីរទាំងឡាយ ដែលគួរកត់សម្គាល់ គឺព្រះសង្ឃភាគច្រើន ដែលមកពីអាស៊ីភាគកណ្តាល។ ឧទាហរណ៍ដូចជា ព្រះថេរៈ អានស៊ិនកៅ មកពីតំបន់ បរថិយ៍។ ព្រះថេរៈ **ក្វាងសេងក្វៃ** ចូលមកតំបន់ លោយ៉ាង នៅក្នុងសតវត្សទី៣ ហើយបានបកប្រែគម្ពីរ **សុខាវ-តីព្យូហៈ** ឬគម្ពីរព្រះសូត្រស្តីអំពីជីវិតគ្មានទីបំផុត នោះជាជនមកពីតំបន់ **សមរកន្ទ។** ក្រៅពីនេះ ព្រះថេរៈ **ធូហ្វាហូ** ឬឈ្មោះជាបាលីថា **ធម្មរក្ស**ដែលល្បីល្បាញក្នុងការបកប្រែគម្ពីរ **សទ្ធម៌បុណ្ឌរីក** មកពីតំបន់ **ទុខារ** ហើយមកតាំងទីលំនៅ។ លោយ៉ាង ឬ ឆាងអាន ពីចុងសតវត្សទី៣ មកដល់ដើមសតវត្សទី៤។ នៅពេលដែល**កុមារជីវៈ** មកពីតំបន់ **កុឆា** បានបញ្ចេញមុខឡើង នៅដើមសតវត្សទី៥ ការបកប្រែគម្ពីរនៅប្រទេសចិនបានឡើងដល់កំពូល។

គឺចាប់ពីសម័យនោះហើយ ដែលពួកព្រះសង្ឃចាប់ចេញពី ប្រទេសចិន ទៅប្រទេសឥណ្ឌា ដើម្បីស្វែងរករៀនភាសាសំស្រ្កឹត និងពុទ្ធវិន័យ។ ក្នុងចំណោមព្រះសង្ឃទាំងនោះ មានព្រះសង្ឃមួយអង្គឈ្មោះ **ហ្វាស៊ី អេន** ៣៣៩-៤២០?។ ព្រះសង្ឃអង្គនេះ ចេញពី លោយ៉ាង នៅប្រទេសឥណ្ឌា ក្នុងឆ្នាំ ៣៩៩ ហើយត្រឡប់មកវិញ ដប់ប្រាំឆ្នាំក្រោយនោះ។ ក្នុងចំណោមព្រះសង្ឃដែលទៅប្រទេសឥណ្ឌា ព្រះថេរៈ ហ្សីអានធូវអាង ឆ្នាំ ៦០២-៦៦៤ មានឈ្មោះល្បីល្បាញជាងគេបង្អស់។ ព្រះសង្ឃអង្គនេះ និមន្តទៅប្រទេសឥណ្ឌាក្នុងឆ្នាំ ៦២៧ ហើយត្រឡប់មកវិញក្នុងឆ្នាំ ៦៤៥ គឺ១៩ឆ្នាំ ក្រោយមក។ ក្រៅពីនោះ មានព្រះថេរៈ អ៊ីធិង ឆ្នាំ ៦៣៥-៧១៣ ព្រះអង្គនិមន្តទៅប្រទេស

ឥណ្ឌា តាមផ្លូវសមុទ្រ ក្នុងឆ្នាំ ៦៧១ ហើយត្រឡប់មកស្រុកកំណើតវិញតាមផ្លូវដដែល ២៥ឆ្នាំ ក្រោយនោះ។

ពួកព្រះសង្ឃទាំងនោះ ទ្រង់និមន្តទៅប្រទេសឥណ្ឌា ដោយចិត្តឯង ដើម្បីរៀនភាសាសំស្ក្រឹត នាំយកមកប្រទេសកំណើតវិញនូវគម្ពីរ ដែលបានជ្រើសរើសដោយផ្ចិតផ្ចង់ ហើយចាប់បកប្រែគម្ពីរទាំងនោះ។ ជាពិសេស ចំណេះខាងភាសាវិទ្យារបស់ព្រះថេរៈ **ហ្សីអានធាង** អស្ចារ្យណាស់។ ដោយសារសកម្មភាពដ៏ខ្លាំងក្លានៃព្រះថេរៈអង្គនេះ ការបកប្រែគម្ពីរនៅប្រទេសចិន បានឡើងដល់ចុងកំពូលមួយទៀត។ ពួកអ្នកប្រាជ្ញបណ្ឌិតខាងពុទ្ធសាសនា ជំនាន់ក្រោយមក បានដាក់ឈ្មោះថា «ភាសាបរិវត្តន៍ចាស់» ចំពោះការបកប្រែដែលធ្វើឡើងនៅសម័យមុនដំបូង ដោយពួកព្រះសង្ឃ ដូចជា ព្រះថេរៈ **កុមារជីវៈ** ជាដើម ហើយដាក់ឈ្មោះថា «ភាសាបរិវត្តន៍ថ្មី» ចំពោះការបកប្រែ ដែលធ្វើឡើងដោយព្រះថេរៈ ហ្សីអានធាង និងពួកអ្នកបកប្រែភាសាជំនាន់ក្រោយៗ មកទៀត។

ដោយពឹងផ្អែកទៅលើគម្ពីរពុទ្ធសាសនាជាច្រើនមហិមា ដែលបានបកប្រែពីសំស្ក្រឹតទាំងនេះ គោលគំនិត និងសកម្មភាពសាសនាជាច្រើនមហិមា នៃអ្នកប្រាជ្ញបណ្ឌិតទាំងនោះ បានជ្រួតជ្រាបបន្តិចម្តងៗ តែប្រាកដប្រជា ទៅក្នុងចិត្តគំនិតរបស់គេ តាមសភាពជាចិននិយម។ ត្រង់នេះបង្ហាញឲ្យឃើញទាំងស្រុងនូវសភាព ពូជសាសន៍ សេចក្តីត្រូវការ និងជំនឿទុកចិត្តទៅលើនិន្នាការនេះ។ ក្នុងវិស័យបរមត្ថវិជ្ជាការដែលព្រះសង្ឃទាំងនោះ តាំងពីដើមដំបូងមក មានគោលគំនិតឆ្ពោះទៅរក «ភាពទទេ» ដែលមាននិទាននៅក្នុង

សាស្ត្រា «ប្រាជ្ញា» ជាពិសេសនោះ ជាការបញ្ជាក់ឲ្យឃើញនូវនិន្នាការនេះ។ ក្រោយមកព្រះសង្ឃទាំងនោះបានបោះបង់ចោលនូវការនិយម ដែលគេហៅថា «ហីនយាន» ឬយានតូច ហើយបែរគំនិតទាំងស្រុងទៅរក «មហាយាន» ឬ យានធំវិញ។ ម្យ៉ាងទៀត និន្នាការនេះកាន់តែច្បាស់ឡើង ជាលំដាប់ នៅក្នុងនិកាយ **តេនដៃ** ហើយគេអាចនិយាយបានថានិន្នាការនេះបានឡើងដល់ចុងកំពូល នៅពេលដែលនិកាយ ហឿន កើតឡើង។

នៅចុងសតវត្សទី៦ និកាយ តេនដៃ បានឡើងដល់ភាពពេញបរិបូរណ៍ នៅក្នុងប្រទេសចិន ក្រោមឥទ្ធិពល តេនដៃដៃស៊ី ឬឈីអ៊ី គ.ស.៥៣៨-៥៩៧ ក្នុងសម្ដេចព្រះសង្ឃរាជទី៣ របស់ខ្លួន។ ឈីអ៊ី នេះ ជាអ្នកតំណាងគំនិតពុទ្ធសាសនានិយមខ្ពង់ខ្ពស់ជាងគេមួយរូប។ ទ្រឹស្ដីបែងចែក ចាត់ជាថ្នាក់ នូវពុទ្ធោវាទ ជា៥កាល និង៨វាទៈ ដែលធ្វើឡើងដោយសន្តបុគ្គលអង្គនេះ មានឥទ្ធិពលខ្លាំងក្លាជាយូរអង្វែង ទៅលើពុទ្ធសាសនាក្នុងប្រទេសចិន ក៏ដូចជាក្នុងប្រទេសជប៉ុនដែរ។

ការស្រាវជ្រាវយ៉ាងល្អិតល្អន់បានបង្ហាញឲ្យឃើញថា សាស្ត្រាទាំងឡាយត្រូវបាននាំចូលមកក្នុងប្រទេសចិន ដោយមិនបានគិតដល់ប្រវត្តិកំណើតនៃសាស្ត្រាទាំងនោះទេ ហើយត្រូវបានបកប្រែជាបន្តបន្ទាប់ នៅពេលដែលសាស្ត្រាទាំងនោះចូលមក។ ចំពោះសាស្ត្រាជាច្រើនអនេកនេះ សំនួរត្រូវបានចោទឡើង អំពីការរកឲ្យយល់នូវដើមកំណើត និងតម្លៃ នៃសាស្ត្រាទាំងនោះ។ ជាការចាំបាច់ ត្រូវតែគិតថ្លឹងតម្លៃព្រះពុទ្ធសាសនា ក្នុងសភាពជាទូទៅ ហើយម្នាក់ៗជាចាំបាច់ ត្រូវតែគិតទៅតាមចំណេះប្រាជ្ញា យល់ឃើញរបស់ខ្លួនផ្ទាល់។ ក្នុងការឲ្យតម្លៃដល់សាស្ត្រាទាំងឡាយ និន្នាការនៃជំនឿ តាមរបៀបចិននិយម មានមុខងារសំខាន់ណាស់។ ការឲ្យតម្លៃតាមជំនឿនៃព្រះថេរៈ ឈី

អ៊ី មានរបៀបរបបជាងគេបង្អស់ ដូច្នេះត្រូវបានគេជឿតាមយ៉ាងអស្ចារ្យ។ ប៉ុន្តែ ដោយការស្រាវជ្រាវពុទ្ធសាសនាសម័យថ្មីបានកើតឡើង ឥទ្ធិពលខ្លាំងក្លានេះ ត្រូវអស់បន្តិចម្តងៗ ជាលំដាប់។

នៅក្នុងប្រវត្តិពុទ្ធសាសនាចិន និកាយដែលកើតក្រោយគេបង្អស់គឺ និកាយហ្សិន។ តាមពាក្យគេនិយាយ អ្នកបង្កើតនិកាយនេះ ជាអ្នកបួសមួយអង្គ មកពីបរទេស មានឈ្មោះថា ពោធិធម៌ ឆ្នាំ ?-៥២៨ ក្រោយគ្រិស្តសករាជ។ ប៉ុន្តែ គ្រាប់ពូជដែលព្រះសង្ឃអង្គនេះបានបណ្តុះ បានប្រកបផលផ្លែផ្កា យ៉ាងរុងរឿង នៅក្រោយរជ្ជកាល ហួយ ណេង គ.ស.៦៣៨-៧១៣ ឯណោះ គឺនៅក្នុងជំនាន់ទី៦ នៃត្រកូលនេះ។ ក្រោយសតវត្សទី៨ និកាយនេះបានបញ្ចេញព្រះសង្ឃជំនាញៗ ជាច្រើន ជាបន្តបន្ទាប់ ដែលបណ្តាលឲ្យនិកាយ ហ្សិននេះបានចម្រើនរុងរឿងក្នុងរយៈជាច្រើនសតវត្ស។

គេសង្កេតឃើញថា ចំពោះព្រះពុទ្ធសាសនា មានការគិតពិចារណាតាមរបៀបថ្មីមួយ ដែលមានឫសគល់យ៉ាងជ្រៅនៅក្នុងចរិតនៃប្រជាជនចិន។ ការនេះ គ្មានអ្វីក្រៅពីពុទ្ធសាសនា ដែលយោលទៅតាមគតិនិយមចិន នោះទេ។ ដោយសារមានចរន្តគតិនិយមថ្មីនេះជាបន្ថែម សាសនាព្រះពុទ្ធគោតម រឹតតែរីកធំឡើងទៀត ហើយបានលូតលាស់សម្បើមនៅចុងបូព៌ាប្រទេស។

# ៥- ប្រទេសជប៉ុន

ប្រវត្តិព្រះពុទ្ធសាសនានៅប្រទេសជប៉ុន ចាប់ផ្តើមឡើងក្នុងសតវត្សទី៦ នៃគ្រិស្តសករាជ។ ក្នុងឆ្នាំ ៥៣៨ ព្រះមហាក្សត្រនៃនគរ ប៉ោឆី ជាភាសាជប៉ុនហៅថា គឹដារ៉ា គឺប្រទេស កូរ៉េ សព្វថ្ងៃនេះ បានបញ្ជូនរាជទូតឲ្យនាំព្រះពុទ្ធរូប

មួយព្រះអង្គ និងសាស្ត្រាមួយក្បាល មកថ្វាយព្រះចៅអធិរាជគិមម៉ី។ នេះជាការនាំចូលនូវព្រះពុទ្ធសាសនា ជាលើកទីមួយ ទៅក្នុងប្រទេសជប៉ុន។ ដូច្នេះប្រវត្តិព្រះពុទ្ធសាសនានៅប្រទេសជប៉ុនមកទល់សព្វថ្ងៃនេះ បានជាង ១៤០០ ឆ្នាំហើយ។

ក្នុងប្រវត្តិដ៏វែងនេះ យើងអាចគិតពិចារណាចំពោះពុទ្ធសាសនាជប៉ុន បានតាមមជ្ឈមណ្ឌលបី។ មជ្ឈមណ្ឌលទី១ គឺព្រះពុទ្ធសាសនា ក្នុងសតវត្សទី ៧ និងទី៨។ ដើម្បីបំភ្លឺការនេះឲ្យបានច្បាស់លាស់ យើងអាចរៀបរាប់អំពីព្រះវិហារហូរីយឺហ្ស៊ី គ.ស. ៦០៧ និងព្រះវិហារ តូដៃហ្ស៊ី គ.ស. ៧៥២។ ព្រះវិហារទាំងពីរនេះ បានសង់ឡើងក្នុងស័យនោះ។ កាលណាគេរំលឹកឡើងវិញអំពីសម័យនោះ គេមិនត្រូវភ្លេចគិតដល់កំពស់វប្បធម៌ដ៏ខ្ពង់ខ្ពស់អស្ចារ្យនៅក្នុងទ្វីបអាស៊ីទាំងមូល នាសម័យនោះទេ។ ក្នុងសម័យនោះ នៅពេលដែលអារ្យធម៌នៅបស្ចិមប្រទេសមានភាពងងឹតជ្រប់នោះ អារ្យធម៌នៅបូព៌ាប្រទេសមានដំណើរយ៉ាងសកម្ម សម្បើមអស្ចារ្យ។ នៅក្នុងប្រទេសចិន អាស៊ីកណ្ដាល ឥណ្ឌា និងប្រទេសឯទៀតៗ នៅតំបន់អាគ្នេយ៍ សកម្មភាពក្នុងវិស័យបញ្ញាវន្តសាសនា និងវិចិត្រកម្ម មានដំណើរខ្លាំងក្លាណាស់។ ស្របជាមួយនឹងចលនានេះ ព្រះពុទ្ធសាសនា បានស្រោចស្រពពិភពខាងកើត នូវចរន្តមនុស្សធម៌ដ៏ធំធេង។ ចលនាថ្មីនៃវប្បធម៌ជប៉ុន ដែលមានសំណង់ព្រះវិហារ ហូរីយឺហ្ស៊ី និងតូដៃហ្ស៊ី ដ៏ល្អឆើតឆាយជាកស្តុតាង ហើយនឹងសកម្មភាពសាសនា និងវិចិត្រសិល្បៈ ប្រកបដោយពណ៌ឆើតឆាយដែលទាក់ទងនឹងព្រះវិហារទាំងនោះជាបន្ទាល់ បង្ហាញឲ្យឃើញច្បាស់ អំពីកំរិតវប្បធម៌ ដែលគ្របដណ្ដប់ទៅលើផ្ទៃដ៏ធំធេងនៃអាស៊ីទ្វីប រហូតដល់ទៅចុងបូព៌ាប្រទេស។

ប្រទេសជប៉ុន ដែលមកទល់ពេលនោះ នៅមានអារ្យធម៌ទន់ទាបនៅឡើយ ក៏ត្រូវបានស្រោចស្រពដោយចរន្តវប្បធម៌ដ៏ធំនេះ ហើយផ្ទៃផ្កានៃអារ្យ-ធម៌ ក៏បានរីកយ៉ាងឆាប់រហ័ស។ នេះជាក័ព្វវាសនាល្អមួយ ដែលប្រជាជនជប៉ុនបានទទួល នៅសតវត្សនោះ។ ដើមហេតុសំខាន់បំផុតដែលបណ្តាលឲ្យមានការលូតលាស់នៃវប្បធម៌នេះ គ្មានអ្វីក្រៅពីព្រះពុទ្ធសាសនាទេ។ វិហារពុទ្ធសាសនាទាំងឡាយនាសម័យនោះ ត្រូវបានជាមណ្ឌលដ្ឋានសំខាន់នៃសង្គម ហើយព្រះសង្ឃទាំងឡាយមានមុខងារជាអ្នកដឹកនាំ ក្នុងផ្នែកសិក្សាអប់រំថ្មីនេះ។ មិនត្រឹមតែផ្នែកសាសនា តែមួយមុខប៉ុណ្ណោះទេ ព្រះសង្ឃទាំងនោះបានពង្រីកចេញជាវប្បធម៌ដ៏ធំទូលាយមួយ។ នេះហើយជាស្ថានភាពព្រះពុទ្ធសាសនា នៅពេលដែលនាំចូលមកក្នុងប្រទេសជប៉ុន មុនដំបូង។

មជ្ឈមណ្ឌលទី២ គឺ ព្រះពុទ្ធសាសនា នៅសតវត្សទី១២ និង១៣។ ក្នុងប្រទេសជប៉ុននៅពេលនោះ បព្វជិតល្បីល្បាញធំៗ ជាច្រើន បានលេចឈ្មោះឡើង ដូចជា ព្រះថេរៈ ហូនេន គ.ស. ១១៣៣-១២១២ ព្រះថេរៈ ស៊ីនរ៉ាន គ.ស. ១១៧៣-១២៦២ ព្រះថេរៈ ដូហ្គេន គ.ស. ១២០០- ១២៥៣ ព្រះថេរៈ នីជីរ៉ុង គ.ស. ១២២២-១២៨២ ជាដើម។ សព្វថ្ងៃនេះក៏ដោយ តែកាលណាគេនិយាយអំពីពុទ្ធសាសនាជប៉ុន គេមិនអាចបរិយាយដោយមិនបញ្ជាក់អំពីបព្វជិតធំៗទាំងនោះបានទេ។ ហេតុដូចម្តេចបានជា បព្វជិតល្បីល្បាញអស្ចារ្យបានកើតឡើង នៅតែក្នុងសតវត្សនោះ ដូច្នេះ? គ្មានអ្វីគួរឆ្ងល់ទេ ពីព្រោះបញ្ហាជាទូទៅមួយ បានកើតឡើងចំពោះមហាបុគ្គល ទាំងឡាយក្នុងសម័យនោះ។ តើបញ្ហាជាទូទៅនោះជាបញ្ហាអ្វីទៅ? មើលទៅប្រហែលជាមកអំពី

ហេតុការណ៍ ដែលព្រះពុទ្ធសាសនាត្រូវបានប្រជាជនជប៉ុនទទួលយក ក្នុងបែបផែនពិសេសជាជប៉ុននិយម។

រឿងនេះនាំឲ្យយើងមានសំនួរថា: ចុះម្ដេច ក៏ដូច្នេះ? ព្រះពុទ្ធសាសនាត្រូវបាននាំចូលមកក្នុងប្រទេសជប៉ុននេះ តាំងពីយូរយារណាស់មកហើយនុ៎ះមិនពិតទេ ឬអី? បើយោលទៅតាមប្រវត្តិសាស្ត្រ រឿងនេះពិតជាអញ្ចឹងមែន។ ប៉ុន្តែរឿងមួយទៀត ក៏ជារឿងពិតដែរ គឺថាប្រជាជនជប៉ុនត្រូវការពេលច្រើនសតវត្សជាចាំបាច់ ដើម្បីអាចនឹងទទួលជឿយ៉ាងពេញលេញនូវសាសនា ដែលនាំចូលមកនោះ ហើយកែទម្រង់ឲ្យទៅជាសាសនារបស់ខ្លួនពិតប្រាកដ។ រួមសេចក្ដីទៅ គឺក្នុងរយៈសតវត្សទី៧ និងទី៨ ដែលប្រទេសជប៉ុនចាប់ផ្ដើមខំប្រឹងខ្នះខ្នែងទទួលយកព្រះពុទ្ធសាសនា ប៉ុន្តែការខំប្រឹងខ្នះខ្នែងនេះ ត្រូវបានផលផ្លែផ្កា ដល់ទៅក្នុងសតវត្សទី១២ ទី១៣ ក្រោមសកម្មភាពនៃព្រះសង្ឃធំៗឯណោះទៅវិញទេ។

ជាបន្តមក ពុទ្ធសាសនាជប៉ុន ដែលបព្វជិតធំៗ ទាំងនោះបានកសាងគ្រឹះហើយនោះ ក៏បន្តសកម្មភាពប្រកបដោយជោគជ័យ រហូតមកដល់សព្វថ្ងៃនេះ។ ក្រោយពីជំនាន់មហាបព្វជិតអស្ចារ្យទាំងនោះមក ពន្លឺភ្លឺឲ្យបានដូចពន្លឺនៅក្នុងសតវត្សនោះ ក៏ឈប់មានឡើងទៀត នៅក្នុងប្រវត្តិពុទ្ធសាសនាជប៉ុន។ ប៉ុន្តែតាមលំនាំអ្នកនិពន្ធសៀវភៅនេះ ហាក់ដូចជាមានរឿងមួយជាពិសេសផ្សេងទៀត ដែលទាក់ទាញអារម្មណ៍យើង គឺ: លទ្ធផលនៃការស្រាវជ្រាវអំពីពុទ្ធសាសនាដើម ដែលបានធ្វើឡើងក្នុងសម័យថ្មីៗនេះ។

តាំងពីពេលដែលប្រទេសជប៉ុនបានទទួលយកជាដំបូងមក ពុទ្ធសាសនាជប៉ុន ស្ទើរតែទាំងមូល ជាពុទ្ធសាសនាមហាយាន នៅក្រោមឥទ្ធិពលពុទ្ធ-

សាសនាចិន។ ជាពិសេស ក្រោយពេលដែលព្រះថេរៈធំៗ នាសតវត្សទី១២ និងទី១៣ បានកើតឡើង ពុទ្ធសាសនាមហាយានជាមូលដ្ឋានធំបង្អស់ រហូតមកដល់សព្វថ្ងៃនេះ ដោយយោលយកពួកអ្នកបង្កើតនិកាយនេះ ជាមជ្ឈ-មណ្ឌល។ នៅក្នុងប្រវត្តិពុទ្ធសាសនាជប៉ុន ការស្រាវជ្រាវអំពីពុទ្ធសាសនាដើម បានចាប់ផ្ដើមឡើង ប្រមាណជាក្រោយពាក់កណ្ដាលសករាជ ម៉ីហ្ស៊ី។ រូបភាពនៃព្រះពុទ្ធគោតម បានចេញឲ្យឃើញឡើងជាថ្មីយ៉ាងប្រត្យក្ស នៅចំពោះភ្នែកអ្នកដែលមានការភ្ញេចគិតថា ពុំមែនពួកអ្នកបង្កើតនិកាយនេះទេ គឺព្រះពុទ្ធ-គោតមនោះឯង ជាអ្នកបង្កើតពុទ្ធសាសនា។ ហើយពួកអ្នកដែលគ្មានគិតអ្វីក្រៅពីសាសនាមហាយាននោះ ក៏បានយល់ច្បាស់ថា នៅក្នុងមហាយាននោះ មានគោលជំនឿជាគ្រឹះមួយទៀត នៃពុទ្ធសាសនា។ ការវិវត្តន៍ថ្មីនេះ ស្ថិតនៅទាំងស្រុងក្នុងផ្នែកទស្សនសិក្សានៅឡើយ ហេតុនេះ មិនទាន់អាចបណ្ដាលឲ្យមាន សកម្មភាពខ្លាំងក្លាខាងជំនឿសាសនា នៅឡើយទេ។ ប៉ុន្តែ ចំណេះវិជ្ជានៃប្រជាជនជប៉ុនក្នុងព្រះពុទ្ធសាសនា ហាក់ដូចជាបានទៅដល់ផ្លូវបត់ធំមួយទៀត។ អ្នកនិពន្ធសៀវភៅនេះ មានបំណងចង់បញ្ជាក់អំពីរយៈដំណើរវិវត្តន៍ថ្មីនេះ ហើយទុកជាមជ្ឈមណ្ឌលប្រធានទី៣ ក្នុងចំណោមមជ្ឈមណ្ឌលប្រធានទាំង៣ ដែលបានចែងពីខាងលើមកហើយ។

II

# របៀបបញ្ជូនព្រះពុទ្ធសាសនាជាបន្តៗ មកជំនាន់ក្រោយៗ

ព្រះពុទ្ធសាសនា ជាសាសនាមួយដែលមានសិក្ខាបទរបស់ព្រះសក្យមុនីជាគ្រឹះ។ ព្រះអង្គទ្រង់បានផ្សាយសិក្ខាបទនេះ ក្នុងរយៈ ៤៥ឆ្នាំចុងក្រោយនៃជីវិតរបស់ព្រះអង្គ។ ដូច្នេះ ពាក្យពេចន៍ទាំងឡាយ ដែលព្រះអង្គប្រើប្រាស់ក្នុងព្រះធម្មទេសនា មានន័យប្រកបដោយអាជ្ញាដាច់ខាត ក្នុងសាសនានេះ។ ព្រះធម៌ទាំង ៨៤០០០ ធម្មក្ខន្ធ និងគណៈនិកាយជាច្រើន ដែលបានកើតមានឡើង សុទ្ធតែមានការទាក់ទងនឹងសិក្ខាបទព្រះសក្យមុនីនេះ។ សៀវភៅទាំងឡាយ ដែលស្ដីអំពីសិក្ខាបទព្រះពុទ្ធ ត្រូវបានគេដាក់ឈ្មោះថា អ៊ីស្សៃក្យូ ឬពាក្យមួយទៀតថា ដៃហុក្យូ ដែលមានន័យថា ប្រជុំគ្រប់សន្ដគម្ពីរ។

ព្រះសក្យមុនី ទ្រង់បានពោលអះអាង យ៉ាងម៉ឺងម៉ាត់អំពីភាពស្មើគ្នានៃមនុស្សជាតិ ហើយទ្រង់បានសម្ដែងធម៌ទូន្មាន ជាពាក្យសាមញ្ញ ច្បាស់លាស់ដើម្បីឲ្យសត្វលោកទូទៅ អាចបានយល់ពេញលេញនូវពាក្យប្រៀនប្រដៅទាំងនេះ។ រហូតដល់ថ្ងៃអវសាននៃជីវិតរបស់ព្រះអង្គ ក្នុងព្រះជន្ម ៨០ ព្រះវស្សា ព្រះអង្គទ្រង់បានបន្តការសម្ដែងព្រះធម្មទេសនា ដើម្បីជាប្រយោជន៍សម្រាប់មនុស្សលោក ឥតដែលបានឈប់សម្រាកមួយវេលាណាឡើយ។

ក្រោយពីព្រះសក្យមុនី ទ្រង់ចូលនិព្វានទៅ ពួកសាវ័កទាំងឡាយរបស់ព្រះអង្គ បានសម្ដែងព្រះធម្មទេសនា ទៅតាមតែសេចក្ដីដែលខ្លួនបានស្ដាប់ឮមក។ ហេតុនេះ ចំពោះការបញ្ជូនសិក្ខាបទនេះជាបន្តៗ មកក្រោយៗទៀត

ការខុសល្អៀងខ្លះៗ ជាការចៀសពុំផុត។ ការភាន់ច្រឡំដោយអចេតនាទាំងនេះ បានកើតឡើងដោយពុទ្ធសាវ័កទាំងឡាយ ដែលគិតតែពីពន្យល់ផ្សាយព្រះសាសនា ទៅតាមសេចក្ដីដែលខ្លួនបានស្ដាប់ឮ និងយល់ឃើញ។

ប៉ុន្តែ ជាការចាំបាច់ ពុទ្ធដីកាព្រះសក្យមុនី ត្រូវតែបញ្ជូនបន្តមកជំនាន់ក្រោយៗ ឲ្យបានត្រឹមត្រូវ និងពិតប្រាកដ ហើយសត្វលោកគ្រប់ជាន់ថ្នាក់ទាំងអស់ត្រូវតែអាចបានស្ដាប់ឮសេចក្ដីប្រៀនប្រដៅរបស់ព្រះអង្គ។ ដូច្នេះហើយព្រះសង្ឃធំៗបានប្រជុំគ្នា ដើម្បីសម្របសម្រួលពាក្យ និងសិក្ខាបទ ដោយសូត្រប្រាប់គ្នាទៅវិញទៅមកនូវរឿងទាំងឡាយ ដែលម្នាក់ៗបានស្ដាប់ឮ ហើយយល់ឃើញ។ ការប្រជុំនេះ បានប្រព្រឹត្តឡើងអស់ជាច្រើនខែ។ ស្នាដៃដែលជាលទ្ធផលនៃមហាសន្និបាតនេះ មានឈ្មោះថា «កេត្សឹហ្សឹ» ឬ«ការរៀបចំឲ្យមានរបៀបរៀបរយ»។ ការនេះបង្ហាញឲ្យឃើញថា តើមហាសង្ឃទាំងនោះមានសេចក្ដីករុណា និងការរួបរួមគ្នាជញ្ជឹងគិតប៉ុនណាដើម្បីបញ្ជូនបន្តនូវពាក្យពិត ដែលព្រះបរមគ្រូទ្រង់បានថ្លែងទុកមក។ សិក្ខាបទដែលបានសម្របសម្រួលហើយនេះ ក៏ត្រូវបានចារទុក ជាលាយលក្ខណ៍អក្សរ។ នៅក្នុងសិក្ខាបទ ដែលបញ្ជូនបន្តមកក្រោយៗ ជាលាយលក្ខណ៍អក្សរនេះ ព្រះសង្ឃធំៗក្នុងសម័យដំបូង បានបញ្ចូលអត្ថាធិប្បាយ និងសេចក្ដីបកស្រាយរបស់ខ្លួនផ្ទាល់ ដែលគេហៅថា «រ៉ុង» ឬ«សេចក្ដីអភិប្រាយ»។ សិក្ខាបទព្រះពុទ្ធ សេចក្ដីអត្ថាធិប្បាយដែលបន្ថែមពីលើ និងពុទ្ធវិន័យ ទាំងបីពួកនេះ ហៅរួមថា «សានហ្សូក្យូ» ឬជាភាសាសំស្ក្រឹត «ព្រះត្រៃបិដក» មានន័យថា «ប្រជុំគម្ពីរទាំងបីផ្នែក»។

«សានហ្សូក្សូ» ឬ «ព្រះត្រៃបិដក» នេះចែកចេញជា «ក្សូហ្សូ»«វីត្សឺហ្សូ» និង «រ៉ុងហ្សូ»។ ពាក្យ «ហ្សូ» បានន័យថា ភាជន៍ ឬ ប្រជុំ។ ពាក្យ «ក្សូ» ជាសំស្ក្រឹតថា សូត្រ សំដៅទៅលើ ពាក្យឱវាទរបស់ព្រះពុទ្ធ។ ពាក្យ «វីត្សឺ» ជាសំស្ក្រឹតថា វិន័យ សំដៅទៅលើច្បាប់ទាំងឡាយដែលទាក់ទងនឹងជីវិតនៃពុទ្ធសហគមន៍។ ពាក្យ «រ៉ុង» ជាសំស្ក្រឹតថា សាស្ត្រា ឬ អភិធម្ម សំដៅទៅលើសេចក្តីអត្ថាធិប្បាយ ដែលព្រះសង្ឃធំៗ បានសរសេរទុកមក។

តាមរឿងតំណាល ព្រះពុទ្ធសាសនាបានចូលទៅក្នុងប្រទេសចិន ក្នុងឆ្នាំទី១០ នៃសម័យ យុង-ពីង គ.ស. ៦៧។ ប៉ុន្តែនៅបច្ចុប្បន្ននេះ គេយល់ថា ពុទ្ធគម្ពីរទាំងឡាយ បានចាប់ផ្តើមចូលមកក្នុងប្រទេសចិន ហើយត្រូវបានបកប្រែនៅវាង ៨២ឆ្នាំ ក្រោយមក គឺក្នុងឆ្នាំទី១ នៃសម័យយាន់-ឈា ឆ្នាំ១៥១ ក្រោយគ្រិស្តសករាជ ក្នុងរាជ្យព្រះចៅអធិរាជ ហាន ក្នុងសន្តតិវង្សហាន ខាងកើត ជំនាន់ក្រោយ។ ចាប់ពីពេលនោះមក ការខំប្រឹងប្រែងបកប្រែគម្ពីរទៅជាភាសាចិន បានប្រព្រឹត្តឡើងជាបន្តៗ ក្នុងរយៈពេលជាង១៧០០ឆ្នាំ។ អត្ថបទចំនួន ១៤២០ បោះចេញជាគម្ពីរ ៥៥៨៦ ក្បាល ត្រូវបានបកប្រែនៅសម័យនោះ។ ការខិតខំរកវិធីរក្សាទុកគម្ពីរ ដែលបានបកប្រែហើយទាំងនោះ បានចាប់ផ្តើមធ្វើឡើង តាំងពីក្នុងសម័យសន្តតិវង្ស វ៉ុយ ៣៨៦-៥៣៥ ប៉ុន្តែការបោះពុម្ព ត្រូវបានចាប់ផ្តើមធ្វើឡើង នៅក្នុងសម័យសន្តតិវង្សសុងខាងជើង ឆ្នាំ ១១២៧។ ចាប់ពីពេលនោះមក ស្នាដៃនៃព្រះសង្ឃចិនធំៗទាំងនោះ ត្រូវបានបញ្ចូលជាបន្ថែមទៅក្នុងពុទ្ធគម្ពីរ ជាហេតុនាំឲ្យគេឈប់ទទួលស្គាល់សៀវភៅទាំងនេះទុកជា គម្ពីរព្រះត្រៃបិដក។ គឺនៅក្នុងសម័យសន្តតិវង្ស ស៊ីអ៊ី

គ.ស. ៥៨១-៦១៨ ដែលប្រជុំសៀវភៅទាំងនេះ ត្រូវបានឈ្មោះថា «អ៊ីស្សៃក្យូ» ឬ សមូហកម្មពេញលេញនៃសន្តគម្ពីរ។ នៅក្នុងសម័យសន្តតិវង្ស តាង គ.ស. ៦១៨-៩០៦ គេបានដាក់ឈ្មោះថ្មីថា«ដៃហ្សូក្យូ» ចំពោះសមូហកម្មគម្ពីរក្បួនច្បាប់វិន័យ នៃព្រះពុទ្ធសាសនានេះ។

ពុទ្ធសាសនាបានចូលទៅក្នុងប្រទេសទីបេត៍ នៅរវាងគ្រិស្តសករាជទី ៨។ ក្នុងរយៈវេលា ១៥០ឆ្នាំ ចាប់ពីសតវត្សទី ៩ ដល់សតវត្សទី១១ ការខំបកប្រែគម្ពីរចេះតែប្រព្រឹត្តទៅជាបន្តបន្ទាប់ រហូតដល់ស្ទើរតែគម្ពីរទាំងអស់ ត្រូវបានបកប្រែជាភាសាទីបេត៍ នៅពេលនោះ។

សរុបទៅ ដោយឃើញថា គម្ពីរទាំងឡាយ មិនត្រឹមតែត្រូវបានបកប្រែជាភាសា កូរ៉េ ជប៉ុន សិង្ហាលេស៍ ខ្មែរ ទូរគី និងភាសានៃបូព៌ាប្រទេសឯទៀតៗ ជាច្រើន តែប៉ុណ្ណោះទេ គម្ពីរទាំងនោះត្រូវបានបកប្រែជាភាសាឡាតាំង បារាំង អង់គ្លេស អាល្លឺម៉ង់ង់ អ៊ីតាលី ជាបន្ថែមទៀតផងនោះ គេអាចសន្និដ្ឋានដោយប្រាកដប្រជាបានថា សព្វថ្ងៃនេះ ការទទួលប្រសិទ្ធិពរព្រះពុទ្ធសាសនា ត្រូវបានរីកសព្វសាយ ពាសពេញសកលលោក។

ប៉ុន្តែ បើគិតពិចារណា ដោយយោលទៅតាមលក្ខណៈដំណើរលូតលាស់ និងដំណើរប្រែប្រួលនៃពុទ្ធសាសនា ក្នុងរយៈពេលជាង ២០០០ឆ្នាំ និងដោយយោលទៅតាមសៀវភៅជាង ១០០០០ក្បាល ដែលបានសរសេរទុកមកនោះ ក៏ឃើញថាពិបាកនឹងដកស្រង់យកន័យពិត អំពីពាក្យសំដីនៃព្រះសក្យមុនីទោះបីមានគម្ពីរ «ដៃហ្សូក្យូ»ដែលប្រជុំគ្រប់គម្ពីរ គ្រប់ច្បាប់វិន័យនៃពុទ្ធសាសនានេះជាជំនួយផងក៏ដោយ។ ដោយហេតុនេះ ជាការចាំបាច់ត្រូវតែដកស្រង់

យកចំណុចសំខាន់ៗពីគម្ពីរ «ដៃហ្សូក្យូ» ដើម្បីធ្វើជាលក្ខណវិនិច្ឆ័យ និងជាមូលហេតុ សម្រាប់ឲ្យបុគ្គលម្នាក់ៗអាចស្តាបនាជំនឿសាសនារបស់ខ្លួនផ្ទាល់។

នៅក្នុងព្រះពុទ្ធសាសនា អាជ្ញាខ្ពស់បំផុតស្ថិតនៅលើពាក្យសំដីទាំងឡាយដែលព្រះសក្យមុនី ទ្រង់បានថ្លែងមក។ ប៉ុន្តែ សេចក្តីទូន្មានរបស់ព្រះពុទ្ធត្រូវតែមានការទាក់ទងយ៉ាងជិតស្និទ្ធ ជាមួយនឹងការពិតនៃជីវិតរស់នៅសព្វថ្ងៃ។ បើមិនដូច្នេះទេ សាសនានេះមិនអាចនឹងបញ្ចូលចិត្តមនុស្សលោកឲ្យជឿយ៉ាងស្មោះទៅលើបានទេ។ ដូច្នេះ ដើម្បីឲ្យសិក្ខាបទនេះ អាចបានទៅជាសិក្ខាបទរបស់បុគ្គលគ្រប់គ្នាទាំងអស់ ជាការចាំបាច់ ត្រូវតែសិក្ខាបទនេះមានភាពជាធម្មតា ជាក់លាក់ មានលក្ខណៈជាសមភាពចំពោះមនុស្សទូទៅ គ្រប់ជាន់ថ្នាក់ ហើយជាងនេះទៅទៀត ពាក្យទាំងឡាយត្រូវតែឲ្យបាន ជាក់លាក់ និងជាពាក្យដែលគេប្រើប្រាស់ក្នុងជីវិតជារៀងរាល់ថ្ងៃ។

សៀវភៅនេះបានចងក្រងឡើង ក៏ដោយសារមានការពិចារណាដូចបានពោលមកពីខាងលើនេះ ហើយជាកេរដំណែលនៃមហាគម្ពីរ «ដៃហ្សូក្យូ» ដែលមានប្រវត្តិជាង ២៥០០ ឆ្នាំ មកហើយ។ ដោយពិត សេចក្តីអធិប្បាយក្នុងសៀវភៅនេះ មិនអាចទុកជាលេញលេញបានទេ។ ពាក្យសំដីរបស់ព្រះពុទ្ធមានន័យជ្រៅ ឥតទីបំផុត គុណធម៌នៃពាក្យទាំងនោះទូលំទូលាយ ឥតព្រំដែន មិនងាយនឹងដាក់តម្លៃបានទេ។

ប៉ុន្តែ យើងខ្ញុំសង្ឃឹមថា សៀវភៅនេះនឹងបានល្អឡើងៗ ហើយបានត្រឹមត្រូវតាមសេចក្តីពិត ជាលំដាប់តទៅ នៅពេលពិនិត្យកែតម្រូវ និងបោះពុម្ពជាថ្មី ជាបន្តៗ ទៅអនាគត។ នេះហើយ ជាសេចក្តីប្រាថ្នារបស់យើងខ្ញុំ។

III

# ប្រវត្តិសៀវភៅ «សិក្ខាបទព្រះពុទ្ធ»

សៀវភៅពុទ្ធសាសនានេះ ជាលទ្ធផលនៃការរើសប្រមូល ពិនិត្យឡើងវិញនូវសៀវភៅដើមជប៉ុន «កម្រងអត្ថបទពុទ្ធសាសនាបកប្រែជាថ្មី» ដែលបោះពុម្ពនៅ ខែកក្កដា ឆ្នាំ ១៩២៥ ដោយសមាគមផ្សាយ «សៀវភៅពុទ្ធសាសនា បកប្រែជាថ្មី» ដែលមានព្រះមហាថេរៈ មឹអាន-គីហ្ស៊ុ ជាអ្នកដឹកនាំ។ សៀវភៅបោះពុម្ពលើកទី១ ជាភាសាជប៉ុននេះ បានចងក្រងឡើងដោយបណ្ឌិត ស៊ីយឺហ្គាគឺ យ៉ាម៉ាបេ និងបណ្ឌិត ជីហ្សេង-អាកានឹម៉ា ព្រមដោយកិច្ចសហប្រតិបត្តិការនៃគ្រូអាចារ្យពុទ្ធសាសនាជប៉ុនជាច្រើនផង ក្នុងរយៈជាង ៥ ឆ្នាំ។

នៅក្នុងសម័យ ស្យូវ៉ា គ.ស.១៩២៦ «អត្ថបទស្តីអំពីពុទ្ធសាសនា ដែលគេនិយមច្រើន» ត្រូវបានបោះពុម្ពជាភាសាជប៉ុន ដោយសមាគមខាងលើនេះ ហើយត្រូវបានផ្សព្វផ្សាយពាសពេញប្រទេសជប៉ុន។

ក្នុងខែកក្កដា ឆ្នាំ ១៩៣៤ នៅពេលប្រជុំសមាជពុទ្ធិកយុវជននៃភូមិភាគ ប៉ាស៊ីហ្វិកទាំងមូល នៅប្រទេសជប៉ុន សៀវភៅ «សិក្ខាបទព្រះពុទ្ធ» ដែលបកប្រែជាភាសា អង់គ្លេស ពីអត្ថបទស្តីអំពីពុទ្ធសាសនា ដែលបានថែងមកហើយពីខាងលើនេះ ត្រូវបានបោះពុម្ពផ្សាយដោយ សហព័ន្ធពុទ្ធិកយុវជន ប្រទេសជប៉ុនទាំងមូល ដោយមានលោក ហ្គូដារដ៍ (Goddard) ជួយជ្រោមជ្រែងផង ដើម្បីទុកជាទីរំឭក។ ក្នុងឆ្នាំ ១៩៦២ ដើម្បីរំឭកថ្ងៃខួបឆ្នាំ

ទី ៧០ នៃការនាំចូលនៃព្រះពុទ្ធសាសនាទៅក្នុងប្រទេស អាមេរិក លោក យ៉េហាន-នីម៉ាតា ដែលជាប្រធានក្រុមហ៊ុន មីត្សឹតូយ៉ូ បានបោះពុម្ពផ្សាយ សៀវភៅ «សិក្ខាបទព្រះពុទ្ធ» នេះ ជាភាសាអង់គ្លេស ម្តងទៀត។

ក្នុងឆ្នាំ ១៩៦៥ នៅពេលលោក នីម៉ាតា បានបង្កើត «មូលនិធិជំរឿន ពុទ្ធសាសនា» នៅទីក្រុងតូក្យូ ការផ្សាយសៀវភៅនេះជាភាសាអង់គ្លេសទៅ ក្នុងពិភពលោកទាំងមូល ត្រូវបានគ្រោងទុកជាសកម្មភាពមួយ របស់មូលនិធិ នេះ។

ដើម្បីសម្រេចគម្រោងការនេះ គណៈកម្មាធិការសើរើពិនិត្យ និងប្រមូល ទុកនូវឯកសារទាក់ទងនឹង «សិក្ខាបទព្រះពុទ្ធ» ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៦៦។ សមាជិកនៃគណៈកម្មាធិការនេះមាន លោកសាស្ត្រាចារ្យ កាហ្ស៊ឹ យ៉ូស៊ី-គីណូ លោកសាស្ត្រាចារ្យស៊ុយឺ-កាណាអូកា លោកសាស្ត្រាចារ្យ ហេ្សន ណូ-អ៊ីស៊ីហ្គាមី លោកសាស្ត្រាចារ្យ ស៊ីងកូ-សាយ៉េគី លោកសាស្ត្រាចារ្យ កូដូ- ម៉ាត្ស៊ឹណាមី លោកសាស្ត្រាចារ្យ សូដុន-បាន់ដូ និងលោកសាស្ត្រាចារ្យ តាកេ មី-តាកាសេ។ លោកសាស្ត្រាចារ្យ ហ្វីមីអូ-ម៉ាស៊ឺតានី លោកសាស្ត្រាចារ្យ វ៉ាដែល និងលោកសាស្ត្រាចារ្យ តូស៊ិស៊ឹកេ-ស៊ីមីហ្ស៊ឹ ក៏បានជួយធ្វើការពិនិត្យ កែតម្រូវនេះដែរ។ ជាលទ្ធផលនៃការពិនិត្យកែតម្រូវនេះ «សិក្ខាបទព្រះពុទ្ធ» ត្រូវវបានបោះពុម្ពផ្សាយចេញក្នុងទម្រង់ថ្មីមួយទៀតជាភាសាអង់គ្លេស- ជប៉ុន។

ក្នុងឆ្នាំ ១៩៧២ លោកសាស្ត្រាចារ្យ ស៊ុយឺ-ណាកាអូកា លោកសាស្ត្រា- ចារ្យ ហេ្សនណូ-អ៊ីស៊ីហ្គាមី លោកសាស្ត្រាចារ្យ ស្ស៊ុយឺ-ហាណាយ៉ាម៉ា លោក

សាស្ត្រាចារ្យ ក្វានសី-តាមួរ៉ា និងលោកសាស្ត្រាចារ្យ តាកេមិ-តាកាសេ បាន ពិនិត្យឡើងវិញ កែសេចក្ដីខុសខ្វះៗ ហើយបោះពុម្ពសាជាថ្មី។

បន្ទាប់មក គណៈកម្មាធិការមួយរួមមាន លោកសាស្ត្រាចារ្យ រីយោតាត ត្ស៊ី ស៊ីអូអ៊ីរិ, តាកេមិ តាកាសេ, ហ៊ីរ៉ូស៊ិ តាស៊ីការ៉ា, ក្វាន់សី តាមួរ៉ា, សូជុន បាន់ដូ និងសូយូ ហាណាយ៉ាម៉ា (និពន្ធនាយក) ត្រូវបានបង្កើតឡើង ដើម្បីបំពេញ បន្ថែមអត្ថបទភាសាជប៉ុននៃ «**សិក្ខាបទព្រះពុទ្ធ**» និងបានបោះពុម្ពផ្សាយនៅ ឆ្នាំ១៩៧៣។

ជាថ្មីម្ដងទៀត នៅក្នុងឆ្នាំ ១៩៧៤ គណៈកម្មាធិការមួយរួមមាន លោក សាស្ត្រាចារ្យ កូដូ ម៉ាត្ស៊ីណាមិ, សូជុន បាន់ដូ, ស៊ិនកូ សាយេគិ, ដូយូ តុគុណា ហ្គា, ក្វាន់សី តាមួរ៉ា និង សូយូ ហាណាយ៉ាម៉ា (និពន្ធនាយក) ត្រូវបានបង្កើត ឡើង ដើម្បីបំពេញបន្ថែមអត្ថបទភាសាអង់គ្លេស នៃ «**សិក្ខាបទព្រះពុទ្ធ**» ដែលពួកគេបានធ្វើឡើងដោយមានកិច្ចសហប្រតិបត្តិការជាមួយ លោក រិច-ឆាទដ៍ រ. ស្ដេនី។ នោះជាការចងក្រងគួបផ្សំគ្នា ជាមួយច្បាប់ជាភាសាជប៉ុន (បោះពុម្ពផ្សាយក្នុងឆ្នាំ១៩៧៣) ដែលជាលទ្ធផលនាំទៅដល់ការបោះពុម្ព ផ្សាយ «**សិក្ខាបទព្រះពុទ្ធ**» ច្បាប់ភាសាអង់គ្លេស-ជប៉ុន។

នៅឆ្នាំ១៩៧៨ លោកសាស្ត្រាចារ្យ ស៊ីហ្គេអូ កាម៉ាតា និងលោកសាស្ត្រា-ចារ្យ យ៉ាស៊ុអាគិ ណារ៉ា បានចូលរួមក្នុងគណៈកម្មាធិការ។ នៅឆ្នាំ២០០១ លោក សាស្ត្រាចារ្យ ខេណេត តាណាកា, សូហ៊ុ វ៉ាតាណាបិ, យោស៊ីយ៉ាស៊ឺ យោណិ ហារ៉ា និងលោកសាស្ត្រាចារ្យ សេនហ្គាគឺ ម៉ាយេដា (និពន្ធនាយកស្ដីទី)បាន ចូលរួមក្នុងគណៈកម្មាធិការនិពន្ធ។

*ក្រោយមក នៅឆ្នាំ២០១៣ សមាគមដើម្បីផ្សាយព្រះពុទ្ធសាសនាបានប្តូរឋានៈរចនាសម្ពន្ធចាត់តាំងរបស់ខ្លួនពី «មូលនិធិសហសាជីវកម្ម» មកជា «មូលនិធិសហសាជីវកម្មដើម្បីប្រយោជន៍សាធារណៈ» វិញ។*

*នៅក្នុងពេលផ្លាស់ប្តូរនោះ សមាជិកនៃគណៈកម្មាធិការនិពន្ធ រួមមាន៖ លោកសាស្ត្រាចារ្យសេនហ្គាគឺ ម៉ាយេដា (និពន្ធនាយក) លោកសាស្ត្រាចារ្យ ហេរុនណូ អ៊ីស៊ីហ្គាមិ, គីយូតាកា គីមួរ៉ា, ខេណោត តាណាកា, ម៉ាគីអូ តាកេមួរ៉ា, យ៉ាស៊ុអាគិ ណារ៉ា, ស៊ីហ្សូកុ យូស៊ីមីហ្ស៊ឺ, យោស៊ីយ៉ាស៊ឺ យោណិហ្សាវ៉ានិង លោកសាស្ត្រាចារ្យ សូហ៊ុ វ៉ាតាណាបិ។ គណៈកម្មាធិការនិពន្ធ ប្រជុំរៀងរាល់ឆ្នាំក្នុងការខិតខំប្រឹងប្រែងធ្វើយ៉ាងណាឲ្យសៀវភៅ* ***«សិក្ខាបទព្រះពុទ្ធ»*** *បានឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃសង្គមបច្ចុប្បន្ន ។*

*កក្កដា ២០១៤*

IV

# តារាងជំពូក


| ជីវិតមនុស្សលោក | ទំព័រ | បន្ទាត់ |
|---|---|---|
| ន័យនៃជីវិត........................................7 | | 14 |
| សភាពបច្ចុប្បន្ននៃលោកនេះ........................153 | | 11 |
| របៀបរស់នៅដោយថ្លៃថ្នូរ............................362 | | 13 |
| ការគិតខុសអំពីជីវិត..................................73 | | 11 |
| ការយល់ត្រូវអំពីជីវិត................................69 | | 1 |
| ការរស់នៅដោយមានលំអៀងទៅម្ខាងៗ...............92 | | 15 |
| ចំពោះអ្នកយល់ច្រឡំ -រឿងល្បើក.....................198 | | 11 |
| ជីវិតមនុស្ស -រឿងល្បើក.............................144 | | 4 |
| បើគេរស់នៅប្រកបដោយសេចក្ដីលោភលន់និងតណ្ហា ..........143 | | 5 |
| តើ មនុស្សជរា មនុស្សឈឺ មនុស្សស្លាប់ | | |
| បង្រៀនអំពីអ្វីដែរ -រឿងនិទាន .......................148 | | 10 |
| ការស្លាប់ ចៀសពុំរួចទេ -រឿងនិទាន.....................150 | | 9 |
| កិច្ចប្រាំប្រការ ដែលគ្មាននរណាម្នាក់អាច | | |
| បំពេញបាន នៅក្នុងលោកនេះ ...........................79 | | 3 |
| សេចក្ដីពិតបួនប្រការ នៅក្នុងលោកនេះ....................79 | | 15 |
| ការយល់ច្រឡំ និងការបានត្រាស់ដឹង ទាំងពីរនេះ | | |
| ចេញមកពីចិត្ត......................................80 | | 15 |

**តារាងជំពូក**

ទំព័រ បន្ទាត់


កិច្ច ២០ ប្រការដែលពិបាក តែប្រសើរថ្លៃថ្នូរ
សម្រាប់មនុស្សសាមញ្ញបំពេញ............................................209 4

ជំនឿ

ជំនឿជាអគ្គី .......................................................................281 5
ជំនឿមានសភាពសំខាន់បី....................................................283 14
ជំនឿ ជាបាតុកម្មមួយ...........................................................285 13
ជំនឿចេញឲ្យឃើញស្តែងឡើងនៅក្នុងចិត្តស្មោះត្រង់.............282 15
ដើម្បីបានយល់សេចក្តីពិត ជាការពិបាក ដូចជាមនុស្សខ្វាក់
ខំប្រឹងធ្វើពិពណ៌នាអំពីទ្រង់ទ្រាយដំរីដោយយកដៃស្ទាប
រឿងល្បើក.........................................................................120 11
តើសភាពព្រះពុទ្ធស្ថិតនៅកន្លែងណា រឿងនេះត្រូវបាន
បង្ហាញបញ្ជាក់ដោយសិក្ខាបទពិតប្រាកដនៃព្រះពុទ្ធ
សាសនា-រឿងល្បើក ............................................................124 12
សភាពព្រះពុទ្ធត្រូវបានលាក់បំពួនខ្លួន
ដោយសារតណ្ហា -រឿងល្បើក ...............................................118 5
ការមានមន្ទិលសង្ស័យ ជាឧបសគ្គរាំងរាជំនឿ ........................286 7
ព្រះពុទ្ធជាបិតានៃលោកទាំងមូល
សត្វលោក ជាកូនចៅរបស់ព្រះអង្គ.........................................60 6
ប្រាជ្ញារបស់ព្រះពុទ្ធធំធេងហើយជ្រៅដូចសមុទ្រ.......................57 13
ចិត្តរបស់ព្រះពុទ្ធពោរពេញដោយសេចក្តីសន្តោសអាសូរ ..........25 1

**សារាដជំព័រ**


| | ទំព័រ | បន្ទាត់ |
|---|---|---|
| សេចក្តីសន្តោសអាសូរ របស់ព្រះពុទ្ធ មិនចេះចប់ទេ | 26 | 16 |
| ព្រះពុទ្ធគ្មានរូបកាយទេ | 23 | 15 |
| ព្រះពុទ្ធទ្រង់បានយោនយកកំណើតមានជារូបកាយ ដើម្បីពន្យល់ ព្រះសាសនាដល់សត្វលោក | 39 | 15 |
| ព្រះពុទ្ធទ្រង់បានយករឿងកើត និងវិនាសទៅវិញនៃរូបកាយ មកបញ្ជាក់ឃើញដើម្បីសត្វលោកជឿ | 39 | 15 |
| ព្រះពុទ្ធទ្រង់ស្រោចស្រង់សត្វលោកបានចាកផុតពីទុក្ខវេទនា ដោយប្រើឧបាយតាមរឿងល្បើក | 32 | 4 |
| ------------------ជ------------------ | 33 | 9 |
| ពិភពនៃពន្លឺត្រាស់ដឹង | 366 | 5 |
| ដើម្បីបានជាអ្នកគោរពតាម ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ | 279 | 1 |
| របៀបរៀនឲ្យចេះរក្សាច្បាប់វិន័យ ចេះសង្រួមចិត ចេះប្រព្រឹត្តតាមគតិធម៌ | 256 | 8 |
| ផ្លូវថ្លៃថ្នូរប្រាំបី | 261 | 6 |
| ផ្លូវប្រាំមួយ ដើម្បីទៅដល់ត្រើយនាយនៃពន្លឺត្រាស់ដឹង | 263 | 11 |
| កិច្ចប្រតិបត្តិត្រឹមត្រូវ ៤ | 263 | 3 |
| ការពិចារណាត្រឹមត្រូវ ៤ | 262 | 11 |
| កម្លាំង ៥ ដើម្បីបានសម្រេចពន្លឺត្រាស់ដឹង | 263 | 8 |
| សភាពធំធេងឥតព្រំដែន ៤នៃចិត្ត | 268 | 1 |
| បុគ្គលដែលយល់សេចក្តីពិតថ្លៃថ្នូរទាំង៤ | 66 | 6 |
| ការស្លាប់ និង ការមិនទៀងនៃជីវិត | 22 | 5 |
| អ្នកបានសូត្រព្រះនាមព្រះពុទ្ធអមិដានឹងបានទៅកើត | | |

ទំព័រ បន្ទាត់
ក្នុងដែនដីបរិសុទ្ធរបស់ព្រះអង្គ ............................................ 177 13
ចូរបណ្ដាឲ្យមានពន្លឺដោយខ្លួនឯង ចូរទីពឹងលើខ្លួនឯង ............ 17 16

## ការហាត់រៀនបំពត់ចិត្ត

ម្នាក់ៗត្រូវចេះយល់រឿងសំខាន់បំផុតរបស់ខ្លួន
-រឿងឧបមា ........................................................................ 235 7
ចូរប្រយ័ត្ននូវជំហានទីមួយរបស់ខ្លួន ...................................... 208 14
ចូរកុំភ្លេចអ្វីដែលខ្លួនស្វែងរក -រឿងឧបមា .............................. 238 5
ដើម្បីបានសម្រេចជោគជ័យក្នុងរឿងទាំងឡាយ
គេត្រូវតែមានការអំណត់ និងការលំបាក -រឿងនិទាន ............ 248 9
ចូរលើកទឹកចិត្តរបស់ខ្លួនជានិច្ច ទោះបីជាមានការមិនបាន
សម្រេចជាច្រើនដងក៏ដោយ -រឿងនិទាន .............................. 271 1
ចូរកុំបណ្ដោយឲ្យចិត្តមានការរើករវ ទោះបីនៅក្នុង
ស្ថានភាពមិនជាទីគាប់ចិត្ត ក៏ដោយ-រឿងនិទាន ...................... 193 10
បុគ្គលដែលយល់ ហើយប្រព្រឹត្តតាមផ្លូវប្រសើរឧត្តម
ប្រៀបដូចជាបានចូលទៅក្នុងទីងងឹត ដោយយក
ពន្លឺទៅជាមួយផង ............................................................... 67 10
គេនឹងបានចេះអំពីជីវិតរស់នៅ នៅគ្រប់ទីកន្លែង
ដែលគេបានដើរទៅដល់-រឿងនិទាន ...................................... 253 8
មនុស្សលោកប៉ុននឹងដើរទៅតាមទិស
ដែលចិត្តរបស់ខ្លួនបញ្ជា ........................................................ 189 11
ចំណុចសំខាន់នៃពុទ្ធវាទ គឺចេះគ្រប់គ្រងចិត្ត .......................... 19 14

**តារាងជំពូក**


| | ទំព័រ | បន្ទាត់ |
|---|---|---|
| ចូរគ្រប់គ្រងចិត្តរបស់ខ្លួន មុនអ្វីៗទាំអស់ | 330 | 1 |
| បើអ្នកគ្រប់គ្រងចិត្តរបស់អ្នកបាន | 190 | 1 |
| សភាពផ្សេងៗ នៃចិត្ត -ល្បើករឿង | 184 | 3 |
| ចិត្តពុំមែនជាអាត្មាអញទេ | 77 | 4 |
| ចូរកុំបណ្តោយឲ្យចិត្តដឹកនាំបាន | 18 | 4 |
| ចូរជម្នះចិត្តរបស់ខ្លួន | 20 | 5 |
| ចូរធ្វើជាម្ចាស់នៃចិត្តរបស់ខ្លួន | 20 | 7 |
| អំពើបាបទាំងអស់ចេញពី កាយ មាត់ ចិត្ត | 138 | 13 |
| ការទាក់ទងគ្នារវាងចិត្តនឹងពាក្យសំដី | 195 | 14 |
| រូបកាយនេះគ្មានអ្វីក្រៅពីរបស់ខ្ចីគេទេ | 225 | 10 |
| រូបកាយនេះពោរពេញទៅដោយ របស់មិន បរិសុទ្ធគ្រប់ប្រភេទ | 204 | 14 |
| ចូរកុំលោភចំពោះអ្វីៗ ទាំងអស់ | 18 | 4 |
| ចូររក្សា កាយ វាចា ចិត្ត ឲ្យបានបរិសុទ្ធ | 192 | 11 |
| ចូរកុំលំអៀងទៅម្ខាងៗ ចូរកុំខំហួសហេតុ-រឿងនិទាន | 269 | 13 |


## ទុក្ខវេទនានៃមនុស្សលោក


| | ទំព័រ | បន្ទាត់ |
|---|---|---|
| ទុក្ខនៃមនុស្សលោកកើតចេញមកអំពីចិត្តមានសេចក្តីជាប់ជំពាក់ | 70 | 16 |
| វិធីការពារទុក្ខ | 23 | 1 |
| ការយល់ច្រឡំនិងការល្ងង់ខ្លៅ ជាមាត់ទ្វារ ទៅកាន់ពន្លឺត្រាស់ដឹង | 96 | 12 |
| វិធីធ្វើឲ្យបានឆ្លងផុតពីទុក្ខ | 180 | 1 |
| កាលណាភ្លើងតណ្ហាត្រូវបានរលត់ ពន្លឺត្រាស់ដឹងនឹងបានសម្រេច | 223 | 6 |

**តារាងជំពូក**


| | ទំព័រ | បន្ទាត់ |
|---|---|---|
| *ចំណង់ចប់ចល់ ជាប្រភពធំបំផុតនៃអវិជ្ជា* ............................. | 136 | 7 |
| *ចូរគិតថា ចំណង់ចប់ចល់ជាពស់វែកពួនក្នុងគុម្ពផ្កា*................ | 136 | 10 |
| *ចូរកុំជំពាក់ចិត្តនឹងផ្ទះដែលឆេះទ្រលោម-រឿងល្បើក* ................ | 32 | 15 |
| *តណ្ហា ជាប្រភពនៃអំពើបាប* ................................................ | 183 | 9 |
| *លោកនេះ ជាភ្លើងកំពុងឆេះ*................................................. | 131 | 14 |
| *នរជនណាសង្វាតចង់បានកេរ្តិ៍ឈ្មោះ និងកិត្តិយស គឺយកភ្លើងដុតខ្លួនឯង* ........................................................ | 185 | 14 |
| *នរជនណាលោភចង់បានទ្រព្យសម្បត្តិគឺបំផ្លាញខ្លួនឯង*......... | 186 | 6 |
| *លក្ខណៈពិសេស នៃជនជាបណ្ឌិត និងជនពាល*.................... | 210 | 13 |
| *ជនពាលមិនយល់កំហុសរបស់ខ្លួនទេ-រឿងល្បើក*................. | 221 | 13 |
| *ជនពាលមើលឃើញតែលទ្ធផល ហើយច្រណែន នឹងគេឯង -រឿងល្បើក* ........................................................ | 222 | 4 |
| *ការដែលជនពាលអាចធ្វើកើត-រឿងល្បើក* ............................ | 231 | 4 |


## ការរស់នៅជារៀងរាល់ថ្ងៃ


| | | |
|---|---|---|
| *ចូរធ្វើទាន ហើយបំភ្លេចកិច្ចនោះ*............................................ | 265 | 7 |
| *ការធ្វើទានប្រាំពីរយ៉ាង ដោយមិនបាច់មានទ្រព្យ*.................. | 265 | 15 |
| *របៀបធ្វើឲ្យចម្រើនទ្រព្យ -រឿងព្រេង*...................................... | 229 | 2 |
| *របៀបបង្កើតសុភមង្គល*......................................................... | 208 | 3 |
| *ចូរកុំបំភ្លេចសប្បុរសធម៌ ដែលបានទទួល-រឿងព្រេង*.............. | 218 | 8 |
| *ចរិតមនុស្ស* .......................................................................... | 141 | 13 |
| *ភ័ព្វអាក្រក់តាមជាប់នរជនណា ដែលប្រាថ្នាការសងសឹក*........ | 207 | 4 |

**តារាងជំពូក**


| | ទំព័រ | បន្ទាត់ |
|---|---|---|
| *របៀបរំងាប់ចិត្តចង់គំនុំ -រឿងព្រេង* ........ | 358 | 11 |
| *ចូរកុំរឹករវនឹងការនិន្ទានៃអ្នកដទៃ-រឿងព្រេង* ........ | 190 | 16 |
| *អ្នកពុំមែនរស់ដើម្បីសំពត់អាវ ចំណី-អាហារ ផ្ទះសំបែងទេ* ...... | 319 | 14 |
| *ចំណីអាហារ និងសំលៀកបំពាក់ ពុំមែនសម្រាប់ការហ៊ឺហា និងការត្រេកត្រអាលទេ* ........ | 181 | 11 |
| *នៅពេលបរិភោគចំណីអាហារ តើអ្នកត្រូវគិតពីអ្វី* ........ | 323 | 15 |
| *នៅពេលស្លៀកសំលៀបំពាក់ តើអ្នកត្រូវគិតពីអ្វី* ........ | 322 | 13 |
| *នៅពេលចូលដេក តើអ្នកត្រូវគិតពីអ្វី* ........ | 324 | 10 |
| *នៅពេលក្ដៅ ឬពេលត្រជាក់ តើអ្នកត្រូវគិតពីអ្វី*........ | 324 | 1 |
| *ក្នុងជីវិតរស់នៅសព្វថ្ងៃ តើអ្នកត្រូវគិតពីអ្វី*........ | 321 | 9 |


**សេដ្ឋកិច្ច**


| | | |
|---|---|---|
| *របស់ទាំងឡាយត្រូវតែប្រើប្រាស់ឲ្យបានត្រឹមត្រូវ -រឿងព្រេង*........ | 343 | 9 |
| *គ្មានសម្បត្តិណាដែលជារបស់ផងខ្លួនរហូតទេ* ........ | 342 | 11 |
| *គេមិនត្រូវប្រមូលរបស់ទុកសម្រាប់តែខ្លួនឯងម្នាក់ទេ*........ | 347 | 3 |
| *វិធីធ្វើឲ្យមានទ្រព្យសម្បត្តិ -រឿងព្រេង*........ | 229 | 2 |


**ជីវិតគ្រួសារ**


| | | |
|---|---|---|
| *គ្រួសារគឺកន្លែងដែលសមាជិកទាំងឡាយ ទាក់ទងគ្នា ខាងផ្លូវចិត្ត* ........ | 338 | 15 |
| *រឿង ដែលបំផ្លាញគ្រួសារ*........ | 331 | 13 |

## តារាងជំពូក


| | ទំព័រ | បន្ទាត់ |
|---|---|---|
| របៀបសងគុណមហាធ្ងន់ដែលមាតាបិតាមានចំពោះបុត្រ....... | 338 | 10 |
| កិច្ចប្រតិបត្តិត្រឹមត្រូវ ដែលបុត្រធីតាត្រូវធ្វើ ចំពោះមាតាបិតា.............. | 332 | 11 |
| កិច្ចប្រតិបត្តិត្រឹមត្រូវរវាងស្វាមីនឹងភរិយា.............. | 333 | 16 |
| ស្វាមីភរិយាត្រូវមានជំនឿដូចគ្នា-រឿងព្រេង.............. | 345 | 9 |

### ផ្លូវសម្រាប់អ្នកបួសអត់ជីលំនៅខ្ជាប់ខ្ជួន

| | | |
|---|---|---|
| អ្នកដែលគ្រាន់តែស្លៀកពាក់ជាសង្ឃ ហើយសូត្រគម្ពីរសាស្ត្រា ពុំមែនជាអ្នកបួសឥតទីលំនៅទេ.............. | 308 | 15 |
| អ្នកបួសឥតទីលំនៅ ពុំមែនជាអ្នកទទួលមរតកវិហារវត្ត និងសម្បត្តិរបស់វត្តអារាមទេ.............. | 304 | 1 |
| បុគ្គលលោភលន់មិនអាចបានជាអ្នកបួសពិតប្រាកដទេ .......... | 304 | 9 |
| ជីវភាពពិតប្រាកដ ដែលអ្នកបួសត្រូវប្រកប.............. | 307 | 4 |

### ជីវិតសមាជិកសហគមន៍ពុទ្ធសាសនិក

| | | |
|---|---|---|
| ន័យអំពីជីវិតសហគមន៍ .............. | 351 | 5 |
| ស្ថានភាពបច្ចុប្បន្ននៃសង្គមក្នុងលោកនេះ .............. | 153 | 11 |
| សមាគម ៣ប្រភេទ.............. | 352 | 11 |
| ជីវិតសហគមន៍ពិតប្រាកដ .............. | 353 | 4 |
| មហាពន្លឺដែលបំភ្លឺភាពងងឹត .............. | 350 | 8 |
| ភាពសុខដុមក្នុងការទាក់ទងគ្នារវាងមនុស្សជាតិ.............. | 354 | 1 |
| របៀបជួយជំរុញសង្គមឲ្យមានភាពសុខដុម.............. | 355 | 9 |
| ឧត្តមគតិនៃពុទ្ធិកសហគមន៍.............. | 354 | 7 |

**តារាងជំពូក**


| | ទំព័រ | បន្ទាត់ |
|---|---|---|
| ឧត្តមគតិនៃសង្គមពុទ្ធបរិស័ទ | 365 | 10 |
| អ្នកដែលបណ្ដាលឲ្យមានការរីករវដល់ច្បាប់រៀបរយ នឹងបានដល់នូវក្ដីវិនាស-រឿងល្បើក | 220 | 4 |
| អ្នកដែលប្រណៃនិន្ទា រករឿងឈ្លោះប្រកែកនឹងអ្នកឯទៀត នឹងបានដល់នូវក្ដីវិនាស -រឿងល្បើក | 220 | 4 |
| ចូរគោរពមនុស្សចាស់ -រឿងព្រេង | 212 | 1 |
| តើសិស្សនិងគ្រូ ត្រូវប្រព្រឹត្តរវាងគ្នានឹងគ្នាបៀបណា | 332 | 4 |
| របៀបចងមិត្ត | 334 | 9 |
| របៀបជ្រើសរើសមិត្តល្អ | 335 | 15 |
| របៀបដែលម្ចាស់ និងអ្នកបម្រើ ត្រូវប្រព្រឹត្តរវាងគ្នានឹងគ្នា | 335 | 3 |
| អាកប្បកិរិយាចំពោះឧក្រិដ្ឋជន | 347 | 14 |
| រឿង ដែលអ្នកបង្រៀនព្រះធម៌ត្រូវយកចិត្តទុកដាក់ | 310 | 16 |

V

# អក្ខរានុក្រមពាក្យសំស្ក្រឹត

**អនាត្ម័ន** : *ភាពគ្មានអាត្មា*

*គឺជាចំណុចសំខាន់ជាងគេមួយក្នុងព្រះពុទ្ធសាសនា។ នៅក្នុងលោកនេះ គ្រប់វត្ថុដែលមាននៅ គ្រប់បាតុភូតដែលកើតឡើង ទីបំផុតទៅ សុទ្ធតែគ្មានខ្លឹមសារពិតប្រាកដ។ ដូចពុទ្ធសាសនាបានពោលអះអាង អំពីភាពមិនទៀង ឬអនិច្ចតា នៃវត្ថុទាំងអស់ យ៉ាងនេះបញ្ជាក់បានយ៉ាងងាយថាភាពមិនទៀងនេះមិនអាចនឹងមានខ្លឹមសារអ្វីមួយ ដែលឋិតថេរទេ។ អនាត្មន អាចប្រែបានម្យ៉ាងទៀតថា «គ្មានអាត្ម័ន» ។*

**អនិត្យ** : *មិនទៀង*

*គឺជាចំណុចសំខាន់មួយទៀត ក្នុងព្រះពុទ្ធសាសនា។ គ្រប់វត្ថុដែលមាននៅគ្រប់បាតុភូតដែលកើតឡើង នៅក្នុងលោកនេះ ប្រែប្រួលជានិច្ច មិននៅដដែលរហូតទេ។ វត្ថុទាំងអស់ តែងតែវិនាសទៅវិញ ក្នុងថ្ងៃណាមួយ ជាមិនខាន។ ការប្រមើលឃើញអនាគតនេះ ជាប្រភពពិតនៃទុក្ខ។ ប៉ុន្តែមិនត្រូវកាត់យល់នូវសេចក្ដីនេះ តាមដោយទស្សនៈទុទិដ្ឋិនិយមតែប៉ុណ្ណោះទេ ព្រោះការវិវត្តន៍ ឬការកើតឡើងវិញ ក៏ជាការសម្ដែងឲ្យឃើញនូវការប្រែប្រួលជានិច្ចនេះដែរ។*

**ពោធិសត្វ** : *អ្នកដែលកំពុងខំប្រឹងបំពេញបារមី ប្រុងនឹងបានត្រាស់ជាព្រះពុទ្ធ*

*ដើមឡើយ ពាក្យនេះត្រូវបានប្រើចំពោះព្រះគោតមសិទ្ធត្ថ មុនព្រះអង្គបានសម្រេចពន្លឺត្រាស់ដឹង។ ក្រោយពេលដែលពុទ្ធសាសនាមហាយានបានកើតឡើង គ្រប់បុគ្គលដែលខំប្រឹងបំពេញបារមី ប្រុងនឹងបានត្រាស់ជាព្រះពុទ្ធ*

ត្រូវបានទទួលឈ្មោះនេះ។ ក្រោយមកទៀត អ្នកដែលយកសេចក្ដីមេត្តាអាសូរជាយាន ដើម្បី ជួយដឹកនាំគេឯទៀតទៅកាន់ភាពព្រះពុទ្ធ ក្នុងពេលដែលខ្លួនឯងផ្ទាល់ក៏កំពុងខំសង្វាតដែរនោះ ក៏ត្រូវបានឈ្មោះថា ព្រះពោធិសត្វដែរ។ តួយ៉ាង អវលោកិតេស្វរៈ ឬ ក្វានណុង ក្សិតិគារភៈ ឬ ហ្ស៊ីហ្សូ មញ្ចុស្រី ឬ ម៉ុនហ្ស៊ឺ ជាដើម។

**ពុទ្ធ** : អ្នកភ្ញាក់រលឹក អ្នកមានពន្លឺត្រាស់ដឹង

ដើមឡើយ ព្រះគោតមសិទ្ធត្ថ ឬសក្យមុនី ទ្រង់បានទទួលព្រះនាមនេះ ក្រោយពេលដែលព្រះអង្គទ្រង់បានសម្រេចពន្លឺត្រាស់ដឹង ក្នុងព្រះជន្ម ៣៥ ព្រះវស្សា គឺប្រមាណជា ២៥០០ ឆ្នាំមុន។ ទោះបីនៅក្នុងគណៈនិកាយណាក៏ដោយ ឬមានជំនឿផ្អៀងទៅខាងណាក៏ដោយ អ្នកកាន់ពុទ្ធសាសនាទាំងឡាយមានគោលបំណងតែមួយគត់គឺ ប្រាថ្នាឲ្យបានជាព្រះពុទ្ធ។ពុទ្ធសាសនាត្រូវបានបែងចែកជានិកាយជាច្រើន ទៅតាមរបៀប ប្រតិបត្តិផ្សេងៗ គ្នាដើម្បីបានសម្រេចភាពព្រះពុទ្ធនេះ។ តាមជំនឿពុទ្ធសាសនាមហាយាន ក្រៅពីព្រះសក្យ-មុនី ដែលជាព្រះពុទ្ធក្នុងប្រវត្តិសាស្ត្រនោះ មានព្រះពុទ្ធជានិមិត្តរូបជាច្រើន ដូចជា ព្រះអិមិតាភៈ ឬអមិដា ព្រះមហាវៃរោចនៈ ឬ ដៃនីជី ព្រះវៃសជ្យគ្រូ ឬ យ៉ាគឺស៊ី ។ល។ ដែលត្រូវបានគេទុកជា និមិត្តរូបនៃពុទ្ធសាសនា។ នៅប្រទេសជប៉ុន ដោយយោលទៅតាមជំនឿខាងពុទ្ធសាសនិយម «ឋានបរិសុទ្ធ» គឺថាអ្នកដែលបានទៅកើត ក្នុងដែនដីបរិសុទ្ធរបស់ព្រះពុទ្ធអមិដា នឹងបានជាព្រះពុទ្ធ គេជឿថា មនុស្សទាំងអស់ ដល់ស្លាប់ទៅ នឹងបានឈ្មោះថា ព្រះពុទ្ធ ជាភាសាជប៉ុនហៅថា «ហុតុកេ»។ ព្រះពុទ្ធជារតនៈមួយ ក្នុងរតនៈទាំងបីនៃពុទ្ធសាសនា។

**ធម៌** : *លទ្ធិពុទ្ធសាសនា*

*គឺសិក្ខាបទ ដែលព្រះពុទ្ធជាទីគោរពបូជានៃលោក ទ្រង់បានទូន្មានប្រៀនប្រដៅ។ សិក្ខាបទនោះ មានចង់ជាគម្ពីរ ៣ប្រភេទ គឺៈ ព្រះសូត្រ ដែលជាសេចក្តីទូន្មានដែលព្រះពុទ្ធបានប្រៀនប្រដៅ ផ្ទាល់ព្រះអង្គ ព្រះវិន័យ ដែលជាច្បាប់ដែលព្រះពុទ្ធបានបង្កើតទុកមក និងព្រះអភិធម្ម ដែលជាសេចក្តីអត្ថាធិប្បាយវែកញែកនូវព្រះសូត្រនិងព្រះវិន័យ ដែលគ្រូអាចារ្យធំៗ ជំនាន់ក្រោយៗមកបានធ្វើ។ ប្រជុំគម្ពីរទាំងបីប្រភេទនេះ ហៅថា ព្រះត្រៃបិដក។ ព្រះធម៌ ជារតនៈមួយក្នុងចំណោមរតនៈទាំងបីនៃពុទ្ធសាសនា។*

**កម្ម** : *អំពើ*

*ន័យដើមនៃពាក្យនេះ គឺ «អំពើ»។ ប៉ុន្តែយោលទៅតាម ទ្រឹស្តីអំពីការទាក់ទងហេតុនិងផល ពាក្យនេះសំដៅទៅលើកម្លាំងសក្តានុភូត មួយបែបដែលជាលទ្ធផលនៃអំពើពីអតីតរបស់យើង។ អំពើនីមួយៗ របស់យើង ផ្តល់នូវផលអាក្រក់ឬល្អ ជាទីសប្បាយរីករាយ ឬជាទុក្ខ ទៅតាមអំពើនោះ។ អំពើទាំងឡាយ មានឥទ្ធិពលជាខ្លាំងទៅលើអនាគតរបស់ខ្លួនយើង ដែលចាត់ទុកថាជាកម្មរបស់មនុស្ស។ គេជឿថា បើអំពើល្អត្រូវបានប្រព្រឹត្តឡើងជាបន្តបន្ទាប់ កុសលល្អនឹងត្រូវបានប្រមូលផ្តុំច្រើនឡើង។ ហើយកម្លាំងផលបុណ្យនោះនឹងមានឥទ្ធិពលជាប្រយោជន៍សម្រាប់អនាគតរបស់យើង។ តាមសិក្ខាបទនេះ មានអំពើបីប្រភេទ គឺៈ អំពើនៃកាយ អំពើនៃវាចា និងអំពើនៃចិត្ត។*

**មហាយាន** : *យានធំ*

*នៅក្នុងដំណើរប្រវត្តិសាស្ត្រពុទ្ធសាសនា មានចរន្តសំខាន់បំផុតពីរ គឺៈ មហាយាន និងថេរវាទ។ មហាយាន ត្រូវបានរីកសាយ នៅក្នុង ប្រទេស ទីបេត៍ ចិន កូរ៉េ ជប៉ុន ។ល។ ថេរវាទ ត្រូវបានរីកសាយ នៅក្នុង ប្រទេស ភូមា ស្រីលង្កា កម្ពុជា ថៃ ។ល។ យានធំ ទទួលដឹកនាំមនុស្សទាំងអស់ដែលវង់ទុក្ខនៅក្នុងលោកវិលកើតវិលស្លាប់នេះ ទៅកាន់ភាពត្រាស់ដឹង ដោយមិនប្រកាន់ការរើកញែក។*

**និព្វាន** : *សេចក្តីស្ងប់បំផុត*

*ពាក្យនេះបានន័យថា «រលត់»។ គឺជាសភាព ដែលគ្រប់រឿងពុករលួយ និងគ្រប់តណ្ហានៃមនុស្សលោកត្រូវបានរលត់សូន្យ ដោយសារការហាត់ហ្វឹកហ្វឺននិងការត្រិះរិះជញ្ជឹងគិតតាមដោយសតិប្រាជ្ញាត្រឹមត្រូវ។ អ្នកដែលបានសម្រេចសភាពនេះ ហៅថា ព្រះពុទ្ធ។ ព្រះគោតមសិទ្ធត្ថ ទ្រង់បានសម្រេចសភាពនេះ ហើយបានជាព្រះពុទ្ធ ក្នុងព្រះជន្ម ៣៥ ព្រះវស្សា។ ប៉ុន្តែ ព្រះអង្គទ្រង់បានសម្រេចសេចក្តីស្ងប់បំផុត ដល់ទៅពេលព្រះអង្គទ្រង់រលត់ខន្ធឯណោះទេ ពីព្រោះគុណវិបត្តិខ្លះ តែងតែមាននៅជាប់នឹងមនុស្សលោក ដរាបណារូបកាយនៅមាននៅឡើយ។*

**បាលី** :

*គឺជាភាសា ដែលគេច្រើនប្រើនៅក្នុងពុទ្ធសាសនាថេរវាទ។ គម្ពីរពុទ្ធ-សាសនាចាស់ជាងគេ ដែលមានបន្តមកដល់យើងសព្វថ្ងៃនេះ ត្រូវបានសរសេរ*

ទុកមក ជាភាសានេះឯង។ បាលី ជាគ្រាមភាសាមួយ នៃភាសាសំស្ក្រឹត ហេតុនេះ បាលីនិងសំស្ក្រឹត មិនសូវខុសគ្នាប៉ុន្មានទេ។ ឧទាហរណ៍ដូចជាសំស្ក្រឹតថា ធម៌ បាលីថា ធម្ម សំស្ក្រឹតថា និវ៌ាន បាលីថា និព្វាន។

**ចារមិតា** : ឆ្លងទៅត្រើយនាយ

គឺបានទៅដល់ឋានព្រះពុទ្ធ ដោយសារវិធីគោរពប្រតិបត្តិផ្សេងៗ តាមពុទ្ធសាសនា។ ក្នុងចំណោមវិធីគោរពប្រតិបត្តិទាំងនោះមានវិធីប្រតិបត្តិប្រាំមួយ ដែលគេតែងតែយកមកប្រើប្រាស់ ដើម្បីឆ្លងពីពិភពវិលកើតវិលស្លាប់នេះ ទៅកាន់ឋាននៃពន្លឺត្រាស់ដឹង គឺមាន ទាន១ ធម្មចរិយា១ សេចក្តីអត់ធ្មត់១ សេចក្តីម៉ឺងម៉ាត់១ ការសង្រួមចិត្ត១ ការយល់ត្រូវ ឬសតិប្រាជ្ញា១។ ពិធីបុណ្យ «ហ៊ីហ្គាំង» បានន័យថា ត្រើយនាយ នៅនិទាឃរដូវ និងវស្សានរដូវ ដែលជាទំនៀមទម្លាប់ជាតិជប៉ុន ចេញមកពីជំនឿនេះឯង។

**ប្រាជ្ញា** : ការចេះដឹង

គឺជាបារមិតាមួយ ក្នុងចំណោមបារមិតាទាំងប្រាំមួយ។ គឺជាមុខងារនៃគតិដែលអាចឲ្យបានយល់ឃើញដោយឥតច្រឡំអំពីជីវិត ហើយបានដឹងជាក់អំពីការពិតនិងការមិនពិត។ អ្នកដែលបានសម្រេចការនេះពេញបរិបូណ៌ ហៅថា ព្រះពុទ្ធ។ គឺជាការចេះដឹងខ្ពស់បំផុត ភ្លឺបំផុត ដែលខុសគ្នាពីប្រាជ្ញានៃមនុស្សលោកធម្មតា។

**សង្ឃ** : *ពុទ្ធសហគមន៍*

*នៅក្នុងពុទ្ធសហគមន៍ មានបព្វជិត និងគ្រហស្ថ ទាំងពីរភេទ។ ក្នុងសម័យជាដំបូង សហគមន៍នេះកកើតឡើងដោយអ្នកបួសប្រុសស្រី ដែលគ្មានទីលំនៅខ្ជាប់ខ្ជួន។ ក្នុងនិកាយមហាយាន អ្នកទាំងអស់ដែលស្វែងរកសភាពជាពោធិសត្វ ទាំងបព្វជិតទាំងគ្រហស្ថ រួមផ្ដុំគ្នាជាសហគមន៍នេះ។ គឺជារតនៈមួយ ក្នុងរតនៈទាំងបីនៃពុទ្ធសាសនា។*

**សំស្ក្រឹត** :

*គឺជាភាសាដើម នៃប្រទេសឥណ្ឌាសម័យបូរាណ។ ភាសានេះ នៅក្នុងក្រុមភាសា ឥណ្ឌូ-អឺរ៉ុប។ ភាសានេះចែកចេញជា វេទសំស្ក្រឹត និងសំស្ក្រឹតបុរាណ។ គម្ពីរពុទ្ធសាសនាមហាយានទាំងឡាយ ត្រូវបានសរសេរជាភាសានេះឯង ហើយបែបនិពន្ធនេះហៅថា «ពុទ្ធសំស្ក្រឹតលាយ»។*

**សង្សារ** : *ដំណើរអន្ទោលទៅមកនៃការវិលកើតវិលស្លាប់*

*ដំណើរអន្ទោលទៅមកមិនឈប់ឈរ នៃការវិលកើតវិលស្លាប់ នៃអតីតកាល នៃបច្ចុប្បន្នកាល នៃអនាគតកាល នៅក្នុងពិភពថ្កើនភ្នែក ទាំងប្រាំមួយពោលគឺ នរក បិសាចអត់ឃ្លាន សត្វធាតុ អសុរា មនុស្សលោក ទេវលោក ទាំងនេះ ហៅថា សង្សារ។ ដរាបណាយើងមិនបានសម្រេចពន្លឺត្រាស់ដឹងទេ យើងមិនអាចគេចរួចពីកង់វដ្តសង្សារនេះទេ។ អ្នកដែលរំដោះខ្លួនរួចពីវដ្ត-សង្សារនេះ ហៅថា ព្រះពុទ្ធ។*

**សុញ្ញតា** : *ភាពទទេ ឥតខ្លឹមសារ*

*គឺការយល់ឃើញថា វត្ថុទាំងអស់សុទ្ធតែអត់ខ្លឹមសារ មិនឋិតថេរ។ គឺជាចំណុចសំខាន់មួយ ក្នុងពុទ្ធសាសនា។ ដោយហេតុតែអ្វីៗ ទាំងអស់ យោលទៅតាមការទាក់ទងហេតុនិងផល វត្ថុអស់ទាំងនោះមិនអាចមានអ្វីជាខ្លឹមសារឋិតថេរ សម្រាប់ខ្លួនផ្ទាល់ទេ។ តែក៏មិនត្រូវគិតថា វត្ថុទាំងអស់សុទ្ធតែអត់ខ្លឹមសារ ឬមានខ្លឹមសារ នោះដែរ។ មនុស្សលោកក្តី វត្ថុធាតុឯទៀតក្តី សុទ្ធតែត្រូវបានស្ថិតនៅក្នុងភាពមិនទៀងនេះឯង។ ដូច្នេះ ការយល់ថា យោបល់ណាមួយ ឬសិក្ខាបទណាមួយ ឬមនោគមវិជ្ជាណាមួយ ទុកជាត្រឹមត្រូវឥតល្អៀងទុំះ ជាការមិនទំនងសោះ។ នេះជាគោលការណ៍សំខាន់មួយ ក្នុងគម្ពីរពុទ្ធ-សាសនាមហាយានស្តីអំពី ប្រាជ្ញា។*

**សូត្រ** : *គម្ពីរ*

*គឺការកត់ត្រាទុកនូវធម្មទេសនារបស់ព្រះពុទ្ធ។ ន័យដើមនៃពាក្យនេះគឺ «ខ្សែ»។ គឺជាសម្រាំងអត្ថបទ ដែលជ្រើសរើសតាមរយៈការស្រាវជ្រាវដ៏ធំធេងក្នុងសាសនវិទ្យា។ គម្ពីរព្រះសូត្រ ជាគម្ពីរមួយផ្នែកក្នុងប្រជុំគម្ពីរ៣ចំណែក ឬព្រះត្រៃបិដក។*

**ថេរវាទ** :

*ជាទំនៀមទម្លាប់ជំនឿពុទ្ធសាសនា នៅភូមិភាគខាងត្បូង។ ថេរៈបានន័យថា ចាស់បូរាណ។ នេះជាក្រុមនិកាយសង្ឃចាស់ៗ ដែលកាន់ធម៌ វិន័យយ៉ាងតឹងរឹង ខុសពីក្រុមសង្ឃខាងមហាយាននៅភូមិភាគខាងជើង ដែលមាន*

*សេរីភាព និងវឌ្ឍននិយមជាង។ ការខ្វែងយោបល់គ្នា ក្នុងពុទ្ធសហគមន៍នេះ បានកើតមានឡើងយ៉ាងឆាប់រហ័ស ក្នុងប៉ុន្មានសតវត្សក្រោយពីព្រះពុទ្ធ ទ្រង់សុគតទៅ នៅពេលដែលព្រះមហាទេវៈ ដែលជាព្រះសង្ឃជឿនលឿនបានអន្ទោកអន្ទោលបកស្រាយដោយសេរីជាងនូវច្បាប់វិន័យពុទ្ធសាសនា ទាំងប្រាំចំពូក។ រឿងនេះបណ្ដាលឲ្យមានការបែកបាក់គ្នារវាង ថេរវាទ នឹងមហាសង្ឃិក។ មហាសង្ឃិកនេះ ក្រោយមក បានទៅជាប្រភពនៃនិកាយមហាយាន។*

**ត្រៃបិដក** : *ល្អីបី ឬប្រជុំនៃល្អីបី*

*គឺប្រជុំគម្ពីរព្រះធម៌ ៣ចំណែក គឺៈ ព្រះសូត្រ ដែលជាពាក្យទូន្មានដែលព្រះពុទ្ធទ្រង់សម្ដែងពន្យល់ ព្រះវិន័យ ដែលជាច្បាប់ដែលព្រះពុទ្ធទ្រង់បញ្ញត្តិ និងព្រះអភិធម្ម ដែលជាបទអត្ថាធិប្បាយពន្យល់នូវច្បាប់វិន័យពុទ្ធ-សាសនា។ ក្រោយមកទៀត សៀវភៅពុទ្ធសាសនា ដែលនិពន្ធដោយ ពុទ្ធ-សាសនបណ្ឌិតធំៗ នៃប្រទេសចិននិងជប៉ុន ក៏ត្រូវបានបញ្ចូលទៅក្នុង ប្រជុំគម្ពីរនេះដែរ។ -សូមមើលពាក្យ ធម៌-*

# មូលនិធិជំរឿនព្រះពុទ្ធសាសនា

*កាលណាគេនិយាយអំពី មូលនិធិជំរឿនព្រះពុទ្ធសាសនា ឬសមាគមផ្សាយព្រះពុទ្ធសាសនា ជាចាំបាច់ គេត្រូវតែរំលឹកអំពី អ្នកជំនួញម្នាក់ឈ្មោះ យ៉េហាន-នីម៉ាតា ដែលជាអ្នកបានបង្កើតក្រុមហ៊ុនធ្វើគ្រឿងប្រដាប់វាស់វែងដោយទៀតទាត់ មួយឈ្មោះ ក្រុមហ៊ុនមីត្សឺតូយ៉ូ ជាង៣០ឆ្នាំ មកហើយ។*

*លោក នីម៉ាតា បានជឿជាក់ថា ជោគជ័យនៃសហគ្រាស នីមួយៗ សម្រេចទៅលើការស្រុះស្រួលសុខដុមគ្នារវាងឋានសួគ៌ ឋានកណ្តាល និងមនុស្សលោក ហើយភាពល្អឥតខ្ចោះនៃចិត្តមនុស្សលោកនឹងបានសម្រេចលុះណាតែមានកិច្ចសហការស្មើគ្នាជាសមតានៃសតិប្រាជ្ញា សេចក្តីករុណាអាសូរ និងសេចក្តីក្លាហាន។ ដោយមានជំនឿមុតមាំនេះ លោក នីម៉ាតា បានខិតខំតាមកម្លាំងដែលអាចធ្វើបាន ដើម្បីធ្វើឲ្យបានរឹតតែប្រសើរនូវបច្ចេកទេសផលិតកម្ម គ្រឿងប្រដាប់វាស់វែង ហើយនិងដើម្បីការចម្រើនលូតលាស់នៃមនោគតិមនុស្សលោក។*

*លោក នីម៉ាតា ជឿជាក់ថា សន្តិភាពសកលលោកអាចកើតឡើងបាន លុះណាតែមនោគតិមនុស្សលោកបានប្រសើរឥតខ្ចោះ ហើយព្រះពុទ្ធសាសនាជាយានសម្រាប់ដឹកនាំទៅកាន់ទីដៅនេះ។ អាស្រ័យហេតុនេះ ជាង៤០ឆ្នាំមកហើយ ដែលលោកដឹកនាំក្រុមហ៊ុនផលិតកម្មរបស់លោក លោក នីម៉ាតា បានខិតខំយ៉ាងអស់ពីសមត្ថភាព ដើម្បីពង្រីក និងផ្សាយព្រះពុទ្ធសាសនា។*

*នៅខែ ធ្នូ ឆ្នាំ ១៩៦៦ លោកនីម៉ាតា បានបង្កើតសមាគមផ្សាយ ព្រះពុទ្ធសាសនាមួយ ដោយថវិកាផ្ទាល់របស់លោក ក្នុងគំនិតជាជំនួយដល់ការខំ*

ប្រឹងប្រែងដើម្បីសន្តិភាពសកលលោក។ យ៉ាងនេះហើយដែលមូលនិធិជំរឿនព្រះពុទ្ធសាសនា បានចាប់កើតឡើងជាអង្គការសាធារណៈមួយ។

តើត្រូវធ្វើដូចម្តេចទៅ ដើម្បីផ្សាយពុទ្ធសាសនា ឲ្យបានដល់គ្រប់ទិសទី ដើម្បីឲ្យសត្វលោកទាំងអស់អាចទាញយកប្រយោជន៍ ហើយបានសប្បាយរីករាយនឹងពន្លឺព្រះមហាប្រាជ្ញា និងព្រះមហាករុណាអាសូររបស់ព្រះពុទ្ធ នេះបាន? នេះជាករណីយកិច្ចរបស់មូលនិធិជម្រឿនព្រះពុទ្ធសាសនា ក្នុងការដោះស្រាយបញ្ហានេះដោយក្តី អំណត់ ដែលជាគោលបំណងរបស់អ្នកបង្កើតមូលនិធិ។

ជាសរុប ការខំខ្នះខ្នែងយ៉ាងអស់សមត្ថភាពដើម្បីផ្សាយពុទ្ធសាសនានេះ គឺជាសកម្មភាពដោយសុទ្ធចិត្ត ដែលមូលនិធិជំរឿនព្រះពុទ្ធសាសនា បានធ្វើ។

សៀវភៅ «សិក្ខាបទព្រះពុទ្ធ» នេះ ជាលទ្ធផលនៃការត្រិះរិះជញ្ជឹងគិតរបស់យើងខ្ញុំ ទៅលើប្រវត្តិសាស្ត្រសាសនានៅប្រទេសជប៉ុន ហើយយើងខ្ញុំជឿថា សៀវភៅនេះជាសៀវភៅតែមួយ ដែលបញ្ជាក់បង្ហាញអំពីសាសនាព្រះពុទ្ធ ក្នុងន័យពិតប្រាកដតាមជប៉ុននិយម។

សៀវភៅនេះ ចងក្រងឡើងជាកូនសៀវភៅ អាចដាក់លើតុសរសេរ ឬដាក់ក្នុងហោប៉ៅបាន ជាការងាយស្រួលដកយកមកអានដើម្បីជាជំនួយចិត្ត-សាស្ត្រ។

មូលនិធិជំរឿនព្រះពុទ្ធសាសនា សូមប្រសិទ្ធិពរ សូមឲ្យសៀវភៅនេះបានទៅដល់ក្រុមគ្រួសារដ៏ច្រើនអនេក និងសូមឲ្យអស់លោកអ្នក បានទទួលការប្រោះព្រំនូវពន្លឺនៃព្រះបរមគ្រូ។